Khmer Story Lovers

# គោលបំណង

៙✧៙

"**បំភ្លេចមិនបាន**" ជាវណ្ណកម្មដែលនាងខ្ញុំសរសេរ ដើម្បីចូលរួមមហោស្រពប្រឡងប្រជែងដណ្ដើមពានរង្វាន់ "**ព្រះសីហនុរាជ**" នាឆ្នាំ ១៩៩៥។

"**បំភ្លេចមិនបាន**" ជាការដង្ហែតាមព្រះមាគ៌ដ៏មហាភ្ញីស្វាង នៃ**ព្រះបិតាអក្សរសាស្ត្រជាតិ** ដែលព្រះអង្គបានរាជានុញ្ញាតឱ្យមានមហោស្រពប្រឡងប្រជែងដណ្ដើមពានរង្វាន់ "**ព្រះសីហនុរាជ**" នេះ ។

"**បំភ្លេចមិនបាន**" ចូលរួមគាំទ្រសមាគមអ្នកនិពន្ធខ្មែរ ដែលបូជាអស់ស្មារតី កម្លាំង ដើម្បីទ្រទ្រង់វិស័យអក្សរសាស្ត្រ ។

"**បំភ្លេចមិនបាន**" អាចជាជំនួយដ៏តូច ក្នុងការសង្គ្រោះភាពរង្គោះរង្គើនៃការស្រុតចុះរបស់ចលនាអក្សរសិល្ប៍ខ្មែរ ដែលបច្ចុប្បន្នត្រូវចលនាសោតទស្សន៍កំពុងលុកលុយដណ្ដើមទស្សនិកជនខ្មែរទូទាំងប្រទេស ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៥

អ្នកនិពន្ធ

# ភាគទី ១

ពន្លឺទិនករចាចសាចតាមចន្លោះស្លឹករុក្ខជាតិនានា ជះចូលផ្ទៃទឹកវាយោបក់មកត្រសៀក រំកិលរលករលេញអង្កាញ់អង្កួចព្រិច ៗ ដូចស្រកាត្រីជះរស្មីព្រាតៗ គួរពេចពិលរមិលមើល ។ នុ៎ះ ហ្ន៎ លើផ្ទៃទឹកថ្លាឆ្វង់ ចាំងផ្ចិតជារូបស្រីម្នាក់សែនស្រស់សោភា បីដូចទេពកញ្ញាក្នុងរឿងនិទាន នាងនាថឈរលើស្ពានយ៉ាងស្ងៀមស្ងាត់ ខ្សែនេត្រាកំពុងគន់មើលស្រមោលភក្ត្រខ្លួនដែលឆ្លុះក្នុងវារី . . . រលករត់មករមេញរលប់ស្រមោលនាងឱ្យរពើតរពើងរូចហួសទៅ. . . ស្រមោលមានភាពនឹងថ្កល់មកវិញ រលកមួយថ្មីច្រានមកដល់រុញស្រមោលឱ្យរំពើកកំរើកទៀត. . . តែកែវភ្នែក ម្ចាស់រូបឥតព្រិចគ្មានរេនៅគន់រូបខ្លួនដោយភ្លឹកភ្លាំង. . . វង់ភក្ត្រស្រីដូចផ្ការីកបំព្រឹម ប្រែរជាជីតភាពស្រពោនចំលែក មិនខុសពីស្រទាប់បុប្ផជាច់ទងជ្រុះចោលលើដី រងកំដៅសូរ្យសែងវែងស្លោកក្រញង់ក្រៀម. . . សរសៃសក់ប៉ើងរចាត់ផាត់រចាយរេរាំតាមកំលាំងព្រះពាយ មកបោសប្រឡែងពាសខ្នងស្រី សរសៃសក់ខ្លះរត់មកគ្របផ្ទៃមុខដ៏ម៉ដ្ឋខៃ រលោងដូចពងមាន់បក ធីតាគ្មានទើសឥតខ្ចីរវល់ លើកដៃផាត់ឡើយ ។ ហត្ថាឆ្វេងក្ដាប់សំបុត្រពីរ-បី ដែលមានស្រោម ដៃនេះសំយុងចុះ សណ្ដូកយ៉ាងល្ហើយតាមដងខ្លួន ផ្ទុយពីហត្ថាស្ដាំប្រែរជា ក្រសោបក្ដាប់តោងបង្កាន់ដៃស្ពានយ៉ាងណែន បីដូចជាខ្លាចស្ពានរបូតចាត់ គ្មានអ្វីជាទីពឹង. . .

"**ធីរិយា**" ជានាមកញ្ញារូបស្អាត ។ ពេលវេលាចេះតែរំកិល ធីតានៅតែឈរថ្មឹងគ្មានកំរើក គ្មានវាចាមួយម៉ាត់ ភក្ត្រាស្ងប់ស្ងួតនៅតែដដែល... ឱហ្ន៎ !

នឹងថានេះជារូបតុក្កតាក៏មិនពិត បើវិរិយាជាមនុស្សមានជីវិតយ៉ាងប្រចក្សទៅហើយ ។ នាងមានអាយុ ១៩ ឆ្នាំ ជាវ័យកំពុងត្រេកត្រអាលនឹងរសជាតិជីវិត ដូចឃ្មុំកំពុងពេញក្បាលទឹក... តែវិរិយា ហេតុអីក៏ស្រីមានចំណោទជីវិតផ្ទុកពេញទ្រូងសែនធ្ងន់ធ្ងរម្ល៉េះ ?

បុរសរូបសង្ហាម្នាក់ចិតក្នុងវ័យប្រមាណ ២២ ឆ្នាំ រត់ពីចំងាយ ត្រចាញ់ជើងមករកវិរិយា តែវភ្នែកគេចាញ់ឆ្កោះឆោមស្រស់ ។ សភាពឈរថ្មឹងរបស់នាង ទាញជំហានបុរសឱ្យឈប់ង៉ក់ ឈរភាំងសំឡឹងមកស្រី... ខ្លួនប្រាណកក្តដាសើមជោគដោយញើស សក់គេប៉ើងក្រញាំស់ ទ្រូងគេផឹតផតជង្គក់ បញ្ជាក់ច្បាស់ថាគេហត់... ហត់ណាស់គឺហត់ព្រោះតែរត់រកវិរិយាសព្វទិសទី ទើបតែមកជួបនាពេលនេះ ។ ពេលដែលខ្សែភ្នែកគេរេមកប៉ះ រូបឆោមឆើត បប្ញូរមាត់គេលេចស្នាមញញឹមស្រស់ ពន្លឺចក្ខុនរៈមានភាពត្រេកអរបំផុត... រស្មីសប្បាយមានតែមួយភ្លែត ស្រាប់តែរលត់ឈឹង នឹង ភាពភ្ញាក់ភ្លាំងរបស់ស្រស់ស្រី...

កក្តដានាំជំហានរំកិលទៅរកធីតាយ៉ាងយឺត ខុសពីពេលមុនគេរត់មកយ៉ាងត្រចាញ់ជើងគ្មានខ្លាចហត់ យុវនមកឈរថ្មឹងក្រោយខ្នងវិរិយា គេសំឡឹងនាងយ៉ាងស្រងូតឥតស្តី...

នួននាងដឹងច្បាស់នូវវត្តមានរបស់កក្តដា ស្រីឥតងាកមករកគេទេ ផងខ្លួនក្តី វង្ងង់ភក្រ្តក្តី ខ្សែនេត្រាក្តី បែរឆ្ពោះទៅទិសណា ទីណា នៅតែរក្សាភាពដដែល ដូចកាលពីគ្មានរូបកក្តដាមកក្បែរ... មានតែម្រាមហត្ថាឆ្វេងដែលក្តាប់សំបុត្រ បានកំរើកច្រចាច់ញីសំបុត្រយ៉ាងស្រាល ត្របកភ្នែកស្រី ព្រិចបន្តិច... បន្ទាប់មកនឹងថ្លល់សំឡឹងស្រមោលខ្លួនក្នុងទឹកដូចដើម... អ្នកខាងមុខ និងអ្នកខាងក្រោយ ឈរថ្មឹងឥតស្តី អស់វេលាជាច្រើន ដង្ហើម... យូរបន្តិចវិរិយា



ហើបមាត់ទាំងឥតងាកក្រោយ :

- បងមករកអូនធ្វើអ្វី ?

- ដើម្បី អង្វរអូន... ឱ្យ... ឱ្យ... ់គេនិយាយលែងចេញ តែដៃគេដាក់ថ្នមៗលើស្មាស្រី ច្រចាច់យ៉ាងស្រាលក្នុងន័យអង្វរ

តែវនួនល្អងនៅស្ងៀម ឥតញោច ឬបែរភក្រ្តមករកអ្នកកំលោះ... បប្ញូរមាត់ដូចស្រទាប់ផ្កាក្រៀម កំរើកតិចៗ :

- អូនមិនអាចកែប្រែចិត្តទេ... អ្វីៗវាធ្វើម្តេចអាចវិលត្រឡប់មកវិញ... អូនសំរេចចិត្ត...

កក្តដាខាំមាត់ ដៃញ័រទន្ទ្រើតអង្រួនស្មាស្រី :

- បងសុំអង្វរ... បងស្រឡាញ់អូន បងមិនអាចរស់ដោយអត់អូនបានទេ...

- អូនមិនស្អប់បងទេ តែអូនមិនអាចស្រឡាញ់បងវិញដែរ... ព្រោះ. . .

- បងមិនស្តាប់ហេតុផលអីទាំងអស់ បងមានបេះដូងសំរាប់អូន . . . សំរាប់តែអូន... អូនកុំបដិសេធ... សំបុត្រការយើងបំរុងនឹងចែកភ្ញៀវហើយអូន ។

ចប់ប្រយោគកម្លោះស្មើរមិនទាន់ ភក្រ្តស្រងូតរបស់ស្រីបែរមកផាំងឆោមស្រស់លើកសំបុត្រការមកមើលស្រែក :

- ស៉ំបុត្រការ ! ់នាងយកសំបុត្រមកខ្ទប់មុខយំសសឹក់ ហ៊ឹក... ហ៊ឹក អូនអាក្រក់... អូនសាវ៉ា អូនជាកាកីសកតែសត្យទិ ២០. . . ទោះយ៉ាងណាអូនមិនអាចរៀបការជាមួយបងបានទេ... បំភ្លេចអូនទៅ... មានគេម្នាក់នៅរង់ចាំអូន... អូនត្រូវត្រឡប់ទៅរកគេវិញ... ហ៊ឹក... ហ៊ឹក...

ស្មើរមិនចប់វាចា នូននាងស្ទុះរត់ទាំងទឹកនេត្រាហូររហាម ប្រាណញ័រ ដង្កក់ឥតងាកក្រោយ. . . កក្កដាចង់ហាមាត់ឃាត់នាងឱ្យឈប់ ដើម្បីរៀបការ នឹងរូបគេ... គេស្រឡាញ់នាង ស្រឡាញ់គ្មានពាក្យប្រដូច គ្មានអ្វីវាស់បាន ស្មាន មិនត្រូវជម្រៅចិត្តស្រឡាញ់ ជ្រៅជាងសមុទ្រធំជាងផែនដី... បាត់នាងគេ ហេងហាង ប៉ែលប៉ោល ល្វល្វេវក្នុងបេះដូង... បេះដូងត្រូវការស្រី តែអណ្តាត តាំងស្តីមិនចេញ បើអតីតកាលនាង គេដឹងទាំងអស់ ។ ជាអតីតកាលដែល ស្រីពិតជាមិនអាចបំភ្លេច... ផ្អែមល្ហែម ជូរចត់ សើចនិងយំ ឡូកឡំកាត់មិន ដាច់ ។ អ្វីដែលពីម្សិល វិរិយាយល់ព្រមចុះខសន្យារួមផ្លូវជីវិតជាមួយកក្កដា អ្វី នោះវាគ្រាន់តែជាសុបិនទាពេលដែលវិរិយាភ័ន្តភាំងពីអតីតកាលមួយភ្លែត មិន ខុសណាពីការស្រម័យនារាត្រីកាលមួយតែប៉ុណ្ណោះ ហើយកក្កដាក៏ព្យាយាមសិក ខ្លួនគេជំនួសបុរសដែលវិរិយាចង់បំភ្លេច . . . កំលោះខំញញឹមសង្ឃឹមវាសនា ឧត្តម បង្ខំចិត្តកាច់ផ្កាវិរិយាដ៏ស្រស់ក្រអូប មកអប់ក្នុងបេះដូង ស្រាប់តែនរនាថ ភ្ញាក់ពីនិទ្រា ស្វាងពីសុបិន វិលទៅរកអតីតកាល បែរខ្នងឱ្យបច្ចុប្បន្នកាល ទុកឱ្យ កក្កដាជាអ្នករងការជូរចត់ ខកចិត្តស្រពោនបេះដូង ។ ចិត្តចង់ឃាត់ព្រោះក្តី ស្នេហ៍ពេញដើមទ្រូង ប៉ុន្តែឃាត់ដើម្បីអ្វី កំលោះអភ័ព្វស្គាល់វិរិយាដូចបាតដៃ... ស្រឡាញ់នាងណាស់ ត្រូវខំបំពេញចិត្តនាងសិន ទ្រាំតស៊ូបៀមទុក្ខសោកម្នាក់ ឯង ក្រែងវេលាល្អធីតាយល់សុបិនម្តងទៀត ។ បើនាងមិនបកមិនបែរបុរស ក៏មិនខឹង អាចថានេះជាសេរីភាពនៃផ្លូវចិត្តរបស់មនុស្ស... ស្នេហាគ្មានការយល់ ព្រមពីភាគីម្ខាងទៀត ជាស្នេហាចុះកិច្ចសន្យាជាមួយទឹកភ្នែក ជាសំរែកនៃជីវិត អោបទុក្ខ តែស្នេហាខកចិត្ត ក៏ជាបេះដូងដែលរបួសពើតផ្សាពិបាកព្យាបាល ដែរ ។ ចំពោះកក្កដាគ្មានថ្នាំពិសេសណាប្រពៃលើសបុប្ផសូគ៌វិរិយាឡើយ...



មិនអាចបំភ្លេចស្នេហ៍គ្រាដំបូងសំរាប់កក្កដា តែកុំភ្លេចថាស្នេហ៍នោះជាសុបិន មួយពព្រិចភ្នែកនៃភាគីម្ខាង ដែលគេស្វាងពីភាពនិទ្រាទៅហើយ ។ តើកំលោះ សល់អ្វីក្រៅពីបេះដូងថ្ងូរថ្ងូច ? ។

# វគ្គទី ២

កំទេចផេះហុយផ្ទោលៗ ជះមកប៉ះកំភួនជើងសខ្ចី ដូចបណ្ដូលចេកស្រីវិរិយា ដែលកំពុងឈានជាន់ពីលើ ។ ជំហានពោះមួយៗ ស្រាលៗ ស្ទើរនឹងកំរើកទៅមុខមិនរួច កែវភ្នែករវេគេយគន់សព្វទិសទី... មានតែគំនរថ្មបាក់បែកគរពូនរប៉ាត់រប៉ាយឥតសណ្ដាប់ធ្នាប់... ដើមចំប៉ាំរលើងគល់ដូលច្រងាង ឆេះខ្លោចក្រៀមខ្មៅដូចធ្យូង ដើមផ្កាក្ដាំងងា ដួលបះដៃ បះជើង របេះរបូតស្លឹកគ្មានសល់ រំលំទៅលើជណ្ដើរប្រេះស្រាំ ។ នៅសល់ដើមរំដួលដ៏ធំ ដែលឋិតឆ្ងាយពីផ្ទះជាងគេឈរជាប់ដី តែស្លឹកស្លោកក្រៀមខ្លះ ខ្លះក៏លាស់ខៀវបៃតងទាំងប្រឹង... វិរិយានាំកាយទៅតោងមែកផ្កាក្ដាំងងា ដែលពឹងពាក់ជណ្ដើរជាបង្អែក... តួចតន់រភ្នែកសំឡឹងសព្វទីឋាន ទឹកនេត្រា ហូរប្រដេញគ្នាពាសថ្ពាល់ កែវភ្នែកប្រឹងរាវរកវត្ថុសំណល់អ្វីដែលព្រះអគ្គីចិត្តខ្មៅបន្សល់ទុក...

ភក្ត្រាស្រីងាកយ៉ាងយឺតទៅជ្រុងម្ខាង... នាងប្រឹងបើកភ្នែកធំ ៗ ក្បិតស្រវាំងនឹងតំណក់ពេជ្រខំច្រាលហូរ ។ នុះហ្ន៎ គំនរថ្មឥដ្ឋបាក់បែកគរ ខ្ពស់កំពស់ជាង ១ ម៉ែត្រ ពីលើខ្មោចព្យ៉ាណូមួយ វិរិយាស្ទុះទាំងញាប់ញ័រ ឱទានម្នាក់ឯងជួសបេះដូង អួលអាក់ :

- ព្យ៉ាណូ !

ស្រមាមទន់ល្វត រើកកាយកំទេចថ្មចេញយ៉ាងញាប់ពីខ្មោចព្យ៉ាណូ រូបរាងប្រដាប់ភ្លេងប្រាកដស្ទើរមើលមិនស្គាល់ក្រោមចក្ខុស្រី. . . វិរិយាឈរមើល



វាយ៉ាងយូរ ទឹកភ្នែកដណ្ដើមហូររហាម បំពង់កស្រីធឹកផត ភ្នែកចេះតែព្រិលៗរហូតជើងទន់ចុះ ក្បាលក្រាបឱ្យកខ្សួលលើព្យ៉ាណូឆេះខ្លោច... នួនស្រីយំគ្រូកយំរង្គើអស់ប្រាណ... សំព្ទវាចាដំអួញលាន់មកអណ្ដឹត អណ្ដក :

- ព្យ៉ាណូ អ្នកជាសាក្សីស្នេហាខ្ញុំ... ពេលនេះរូបអ្នកវិនាស តើស្នេហាខ្ញុំនិងបងភិរក្សរលាយដែរឬ ? ហ៊ឹក... ហ៊ឹក...

ស្រីយំ... យំ... យំ... យំ ឥតឈប់ឈរ យំតំអួញលាន់ប្រណាំងជាមួយស្នូរវាយោ បក់ពោកផាត់ស្លឹកចំប៉ា ស្លឹកក្ដាំងងាដែលជ្រុះរប៉ាត់រប៉ាយ រាយរាត់លើដី ឱ្យរត់ត្រសៀកប្រដេញគ្នាទៅមុខតាមសន្ទឹកជំនោរបក់ ដូចពាក្យពេចន៍ឆោមកំសត់រៀបរាប់ឥតអាក់ លាន់ពីក្រអូមមាត់ញ័រទទ្រើកនៃបេះដូងទួញយំ...

អតីតកាលផុសភ្លែតៗឡើងក្នុងខួរក្បាល ដូចខ្សែភាពយន្ត កាលពីឆ្នាំ ១៩៧៩ វិរិយាមានឈ្មោះដើមថា "ចរិយា" នាងជាក្មេងកំព្រា កាលណោះនាងមាន អាយុ ៦ឆ្នាំ ឪពុកម្ដាយក្មេងស្លាប់ដោយសាររបប ប៉ុល ពត ។

លើផែនដីដ៏ធំធេង "ចរិយា" រស់ក្បាលមួយ តែលតោលរសាត់អណ្ដែតអត់ទីពឹង គ្មានជំរក របរចិញ្ចឹមជីវិតរបស់ក្មេង គឺដើរសុំទានគេគ្រប់ច្រកល្ហក ។ ទ្រព្យសម្បត្តិពិសិដ្ឋរបស់ចរិយា មានតែសំពត់ខ្មៅកញ្ចាស់រហែករយ៉ៃ អាវខ្មៅពភ្លក់រហែកច្រៀតធៀត ពណ៌ឡើងប្រផេះ សខ្ចង មើលស្ទើរមិនស្គាល់ជាពណ៌អ្វីឱ្យចំ ។

ព្រះអាទិត្យរះថ្មើរណា ជើងចរិយាឈានតត្រុក ជាមួយដៃកាន់ផ្ដិលរយះមាត់ ដើរចច្រប់តាមផ្ទះតាមផ្លូវ... កាកសំណល់ជាទាន ក្មេងទទួលដោយរងនូវពាក្យស្ដីបន្ទោស គំរោះគំរើយ រមាំងរមៅក ។ ដៃលើកចាយពម

ពមជាមួយទឹកភ្នែកប្រដេញកាត់ផែនថ្ពាល់ផតខ្លង . . . កំសត់ខ្លួនពន់ពេក តែចរិយាគ្មានពំនឹងជ្រកកោន. . .

យប់ត្រង់ណា ត្រង់ហ្នឹងជាជំរក ព្រះធរណីជាគ្រែពូកវិចិត្រ ផ្ទៃមេឃអមដោយតារា ឫដួងច័ន្ទជាចង្កៀង លំហអាកាសជុំវិញខ្លួនជាស្បៃមុង ។ ជីវិតកំព្រា កំញើញក្មេងឱ្យរស់ក្នុងភាពរន្ធត់ ជោគជាំជាមួយការភ័យខ្លាច... រាត្រីដ៏ខ្មៅងងឹត ក្មេងខ្លាចញាក់សាច់ ដេកមិនលក់ អង្គុយឱបដៃកំព្រោន១ បើកភ្នែកម៉ក់ៗ សំឡឹងជើងមេឃ បន់ឱ្យថ្ងៃឆាប់រះ... ជំនោររាត្រីបក់មក ក្មេងកំព្រារងារញ័រតត្រុនរណ្ដំថ្លាម បើសិនជាមានព្រះពិរុណបង្អុរផង នោះភាពវេទនាពិតជារៀបរាប់មិនអស់ ។ ជួនកាលសត្វកណ្ដុរតូចសោះ យំឆ្លងឆ្លើយគ្នា វីរិយាភ័យសស្លើត ដេកមិនលក់ អង្គុយយំគគ្រុក ។ មានយប់មួយនោះ ថ្កែដេញព្រូសដណ្ដើមកន្លែងនាងដេក នាងតូចរត់សស្លើត ភ្នែកនៅកញ្ចឹងក យំសសឹករត់កាត់ភាពអន្ធការស្ងួនស្ងុង មិនដឹងស្រែកហៅ ឱ្យនរណាជួយ បើគ្មានម៉ែ គ្មានឪ គ្មានញាតិសន្តាន... ក្មេងរត់... រត់ទៅបុក យុទ្ធមិត្តកងទ័ពម្នាក់កំពុងដើរល្បាត... គឺពេលនោះហើយដែលទំព័រជីវិត វីរិយាប្រាសចាកភាពតែលតោល ត្រម៉ង់ត្រមោចមករស់ក្នុងមជ្ឈមណ្ឌលកុមារ ដែលមាតុភូមិបានបង្កើតក្នុងបំណងស្រោចស្រង់វាសនាលិចលង់របស់កុមារកំព្រា រាប់ម៉ឺនសែននាក់ ។

ជីវិតថ្មីក្នុងមជ្ឈមណ្ឌលកុមារ ចរិយាបានស្គាល់សំណើច... ទឹកភ្នែកលាយច្របល់ជុំបាយ ជំនួសដោយពាក្យផ្អែមល្ហែមពីលោកគ្រូ អ្នកគ្រូ... សុវីរកសប្បុរិភ័យនារាត្រីកាល ជ្រះរំលងពីអារម្មណ៍ ប្ដូរដោយភាពកក់ក្ដៅនៃភួយមុងនិងហ្វូងមិត្តភក្តិជុំជិតយ៉ាងច្រើននាក់. . . ពាក្យសំដីប្រៀនប្រដៅឧត្ដម ១ ម៉ូរជាមាសពេជ្រក៏ថ្លៃមិនស្មើ ដែលលាន់ពីបបូរមាត់ស្រទន់ក្នុងន័យករុណា សន្ដោស



របស់លោកគ្រូ អ្នកគ្រូ មានជានិច្ចមកកាន់រូបនាង ។ មជ្ឈមណ្ឌលផ្ដល់ទ្រព្យមរតកជាចំណេះវិជ្ជា ជាជំនាញកាត់ដេរ គូររូប លេងព្យ៉ាណូ និង ច្រៀង ។ មែនហើយ ក្មេងធ្លាប់ភ្លក់ជ្រក់ជ្រេញជាមួយក្ដីវេទនា ជាមួយការលំបាក ខ្លាចណាស់វេទនា ខ្លាចណាស់លំបាក និង ស្អប់ណាស់សំដីមើលងាយមើលថោកពីមនុស្សមានរំពឹងមានញាតិផៅ ឥឡូវពេលវេលាល្អសំរាប់នាងបានមកដល់នាងប្រឹងតស៊ូស្រវាស្រទេញ អត់ធ្មត់ដណ្ដើមយកអ្វី ១ មកក្នុងដៃ ដើម្បីចៀសឱ្យផុតពីលំបាក ពីវេទនា ពីភាពអត់ឃ្លាន ដែលមនុស្សធ្លាប់មើលងាយមើលថោកដល់រូបនាង ។ មជ្ឈមណ្ឌលជាផ្ទះរួមរបស់ក្មេងកំព្រា ពុំមែនផ្ទះវីរិយាផ្ទាល់ ។ អ្នកគ្រូ លោកគ្រូ ពុំមែនជាឪពុកម្ដាយបង្កើត តែចំពោះវីរិយា ទាំងអស់នេះជាជីវិតដែលពោរពេញដោយកំណាប់សុភមង្គលពិត១ ។ ថ្វីបើអារម្មណ៍ហេងហាង លបលួចកើតមានម្ដង១ដល់រូបស្រីកំព្រា ដែលជាប្រការចៀសមិនផុតតែប៉ុណ្ណោះ ប៉ុន្តែសំរាប់តុរណី មជ្ឈមណ្ឌលជាឋានសួគ៌ជីវិតហើយ ។

"**វីរិយា**" ជានាមថ្មី ដែលសាលាបានសន្មត់ដាក់ឱ្យចរិយា ក៏ព្រោះតែតូចតន់មានចិត្តអំណត់ប្លែក ពូកែតស៊ូប្រមូលស្រូបបាននូវចំណេះ និង ជំនាញច្រើនមុខជាងមិត្តភក្តិទាំងឡាយ ។ អាយុបាន ១៨ឆ្នាំ វីរិយាប្រឡងជាប់មធ្យមសិក្សាកំរិតទីពីរជាស្ថាពរ អមដោយការស្ទាត់នូវជំនាញជាច្រើនមុខផង ។ ការគិតគូរសំរាប់អានាគតនាថ្ងៃស្អែក តែងតែកើតមានដល់ អារម្មណ៍ធីតាកំព្រា...

ថ្ងៃមួយ វីរិយាអង្គុយក្រោមដើមស្វាយ ពោរពេញដោយម្លប់ត្រឈឹងត្រឈៃ ។ ខ្យល់បក់ល្ហៀក១បំពេអារម្មណ៍ស្រីឱ្យលង់ជ្រៅ ក្នុងការត្រិះរិះពិចារណាពីទិសដៅជីវិត តើនាងធ្វើអ្វី ដើម្បីឱ្យរស់សមជាមនុស្សមានប្រយោជន៍ដល់ខ្លួន និង សង្គមជាតិ ? វីរិយាប្រាថ្នាចាកចេញពីមណ្ឌលកុមារ

នាងមិនចង់បង្កការលំបាកដល់ទីនេះ បើមជ្ឈមណ្ឌលមានបន្ទុកសំរាប់វាសនាក្មេងកំព្រារាប់ម៉ឺននាក់ បន្សល់ពីសង្គ្រាម ។ ចំពោះវិរិយា ពេលវេលាដែលលទ្ធភាពអាចឱ្យនាងរស់ដោយខ្លួនឯង បានឈានមកដល់ដែរ គួរអីនៅរស់បន្ថែមទម្ងន់លំបាកដល់លោកគ្រូ អ្នកគ្រូ និង សាលា ។ ស្រាប់តែមានសំឡេងមួយបន្លឺផ្តាច់ ការរិះគិតរបស់នាង :

- ហ្អាក ! វិរិយា ឯងនៅទីនេះទេឬ ?

- មានការអ្វីឬនារី ?

- អ្នកគ្រូញ៉ាណូ ចង់ជួបឯងណាំ ។ អំបាញ់មិញ គ្នាឮគាត់សួររកឯងពីកក្កដាទៀតផង តែកក្កដាជំរាបគាត់ថា មិនដឹងជាឯងនៅទីណាទេ ។

- អូហ៍ អរគុណនារី ចាំគ្នាទៅជួបគាត់ ។

នារីងក់ក្បាលទទួលពាក្យអរគុណពីមិត្ត ទាំងភ្ជាប់ស្នាមញញឹមមុននឹងដើរហួសទៅ ។ វិរិយាងើបយាត្រា នាំប្រាណតំរង់ទីចាត់ការសាលាយ៉ាងរលះរលាំង ។

ក្នុងបន្ទប់ការិយាល័យរបស់អ្នកគ្រូសោភា ដែលជាគ្រូខាងញ៉ាណូ វិរិយាអង្គុយទល់មុខអ្នកគ្រូដោយកាយវិការសុភាពរាបសា អាកប្បកិរិយា នាងរង់ចាំស្តាប់ប្រសាសន៍អ្នកគ្រូ ។ វាចាស្រទន់របស់អ្នកគ្រូបានបន្លឺ :

- អ្នកគ្រូមានមិត្តភក្តិជិតដិតម្នាក់ "អ្នកគ្រូបង្ហង់បន្តិច លើកសំបុត្រមួយមកបង្ហាញវិរិយាពោលបន្ត "... នេះជាសំបុត្ររបស់គេ គេឈ្មោះភិរក្ស ។ ក្នុងសំបុត្រគេ គេត្រូវការឱ្យអ្នកគ្រូជ្រើសរើសរកគ្រូម្នាក់ដើម្បី បង្រៀនកូនស្រីគេ ។ គ្រូដែលគេចង់បាន មានល័ក្ខខ័ណ្ឌច្រើនប្រការ ដែលមានរូបវិរិយាឯងអាចបំពេញបាន ។ ចំពោះអ្នកគ្រូ ៗ ជឿថាក្រៅពីឯងពិតជាពិបាក ព្រោះ. . .



អ្នកគ្រូ បង្អង់សំដី សំឡឹងមុខធីតាហាក់ចង់ស្ទាបស្ទង់ប្រតិកម្មស្រី មែនវិរិយាងើបមុខភ្នែត តបវាចាដោយគោរព :

- អ្នកគ្រូព្រោះអ្វី ? ហេតុអីក៏ខ្ញុំ...

អ្នកគ្រូសោភាញញឹម រាដែតបសំដីទន់ភ្លន់ដូចមុន :

- ឈប់ កូនយ៉ា ! អ្នកគ្រូស្គាល់កូនណាំ "អ្នកគ្រូច្របាច់ដៃនាងស្រាល១" ភារីកូនរបស់ភិរក្ស ជាក្មេងទំរើសបំផុត ឪពុកថ្នមដូចកែវ ធ្វើឱ្យក្មេងរឹងរូស បណ្តាលឱ្យគ្រូរត់ចោលវាអស់ចំនួន៥នាក់មកហើយ ទោះជាឪពុកក្មេងផ្តល់កំរៃជាច្រើនដល់គ្រូទាំង ៥ នោះក្តី ក៏ពួកគេទ្រាំទ្រចរិតទំរើសរបស់ក្មេងមិនបានដែរ ។ ចំណែកកូនយ៉ាឯងវិញ កូនពូកែតស៊ូ ប៉ិនអត់ធ្មត់ចំពោះការលំបាក និងឆ្លាតវៃណាស់ ។ និស្ស័យល្អ១ទាំងនេះជាកត្តាអាចទប់ទល់ក្មេងរបៀបភារីបានយ៉ាងងាយណាំ ហើយក៏ដូចជាស្របនឹងបំណងកូនប្រាថ្នារកការងារដើម្បីចិញ្ចឹមខ្លួនដោយខ្លួនឯង ផងនោះអី ។

សំដីពន្យល់របស់អ្នកគ្រូ បញ្ជាក់នូវសមានចិត្តអ្នកគ្រូចំពោះនាង វិរិយារំភើបពន់ពេក ស្រីផ្តុំហត្ថាទាំងញ័រទទ្រើត សំពះមាតាទីពីរ :

- អ្នកគ្រូ ! កូនអរគុណអ្នកគ្រូ ដែលបានគិតគូររូបកូន ។

សោភាគ្រូចិត្តធម៌ ក្តោបដៃសិស្សសំណព្វ ស្រីដីទាំងញញឹម :

- គ្រូមិនប្រាថ្នាពាក្យអរគុណទេ កូនកំព្រាទាំងអស់ គឺជាកូនរបស់អ្នកគ្រូ អ្វីដែលកូន ៗ អាចទទួលបាន ហើយអ្វីដែលអ្នកគ្រូជួយកើត គ្រូត្រូវតែផ្តល់ដល់កូន១ ណាំ ។

- អ្នកគ្រូ ដើម្បីឱ្យសមនឹងទំនុកចិត្តអ្នកគ្រូ និងសមជាទំពាំងស្នងឫស្សីកូននឹងខិតខំបំពេញកិច្ចការដែលអ្នកគ្រូផ្តល់ឱ្យ ទោះជាត្រូវលុយភ្លើង ឬ ឆ្លង

សមុទ្រ ក៏កូនមិនថយក្រោយដែរ ។

- ល្អណាសិរីវិយា ! បំណងប្រាថ្នាគ្រូមុខជាសំរេច ឯកូនប្រាកដជាស្គាល់ភាពសុខសាន្តច្រើនជាងពេលនេះ ព្រោះភិរក្សជាអ្នកមានស្តុកស្តម្ភ ប្រកបដោយ ចិត្តទូលាយបំផុត គ្រាន់តែគេឆ្មើងឆ្មៃបន្តិច ។ ទំហំការងារកូនវាពិតជាពិបាកទ្រាំ ឯលទ្ធផលល្អមុខជារត់រកកូន មិនខាតកំលាំងឥតអំពើទេ ។ នេះជាជំនឿរបស់អ្នកគ្រូណាំ ។

ឆោមឆើត លើកដៃសំពះអ្នកគ្រូសោភា ជាលើកទីពីរ :

- មួយជំហានទៅមុខ កូនមិនថយក្រោយមកវិញ ដោយឥតបានលទ្ធផលឡើយអ្នកគ្រូ ។ កូនសន្យាថា អ្វីដែលអ្នកគ្រូចង្អុល កូននឹងទំលុះទៅមុខមិនឱ្យខុស បំណងអ្នកគ្រូទេ ។



# វគ្គទី ៣

**វិរិយា** បានមកដាន់ទឹកដីខេត្តកំពង់ចាម ដែលជាគោលដៅហើយ។ ភូមិគ្រឹះលោកភិរក្សបែរមុខទៅរកមាត់ទន្លេ មានភាពស្គឹមស្គៃ សង់ជាពាជាន់បែបម៉ូតអាមេរិក អើតខ្លួនយ៉ាងសង្ហាកណ្តាលផ្ទាដីទំហំជាង ៣ ហិកតា ប្រកបដោយសួនឧទ្យាន បុប្ផគ្រប់ពណ៌ដេរដាសចំរុះ មានចំប៉ី ចំប៉ា ក្តាំងងា ម្លិះលា ម្លិះរួត ទូនស្រី កូឡាប ចន្ទ រំយោល មាលតី... ជះគន្ធពិដោរឈ្ងុយឈ្ងប់ ។ ក្នុងបរិវេណដីនាចំហៀងខាងកើត មានទោងតូចមួយសំរាប់កុមារ ក្បែរទោងជាទ្រើងផ្កាអ័រឃីដេ រាប់សិបដើមព្យួររយីងរយោង ពណ៌ស ពណ៌កូឡាប ក្រហម ស្វាយ លឿងទុំ លឿងខ្ចី ខ្លះរីក ខ្លះក្រពុំ គួរគយគន់ ។ មិនឆ្ងាយពីទ្រើងអ័រឃីដេ អាងហែលទឹកដ៏ប្រណិតមួយ ក៏ជាលំអបង្កើតសំរស់ដល់ភូមិគ្រឹះស្តុកស្តម្ភនេះដែរ ខាងលិចផ្ទះ ស្រះមួយមានផ្កាឈូក ផ្ការំចង់អើតករហង់រង់ចាំសួស្តីអ្នកដែលបានទស្សនាវា ក្បែរមាត់ស្រះ ដើមរំដួលមានមែកត្រកុំត្រកាលពោរពេញដោយផ្កា ជះម្លប់សាខាគ្របដណ្តប់ផ្ទៃស្រះអស់មួយចំហៀង ។ មិនឆ្ងាយប៉ុន្មានពីស្រះ ផ្ទារាបធេង ក្រាលស៊ីម៉ង់ត៍ សំរាប់ជាទីកំសាន្តកីឡាប្រចាំគ្រួសារ ព័ទ្ធជុំវិញផ្ទាជាវាលស្មៅជប៉ុនកាត់តំរឹមស្មើត្រឹម ពណ៌បៃតងស្រងាត់សែនត្រជាក់ភ្នែក. . . ឱ ! ទីផ្ទះដ៏ប្រណីត អ្នកប្រៀបបីដូចជាឋានតុសិត ដែលចាស់ៗ ធ្លាប់និទានប្រាប់កុមារទេដឹង ?

វិរិយា ឈរសំឡឹងភាពថ្កុំថ្កើង ល្អល្អះនៃសោភ័ណភាពភូមិគ្រឹះ ទឹកមុខឆោមស្រី មានភាពនឹងថ្កល់ក្នុងការពិចារណាពីជីវភាពម្ចាស់ផ្ទះដែលនាងត្រូវ

ជ្រកកោន ។ មួយសន្ទុះពីតាល្មកដៃចុចលើកណ្ដឹងដែលនៅជាប់របង ។ ស្ទីរ៉ុង រ៉ុង ! រោទិ៍ឡើង ស្រីបំរើម្នាក់ថិតក្នុងវ័យប្រមាណ ៣៥ឆ្នាំ មានសំលៀកបំពាក់សមសួន លំអដោយអល្អង្កាជាខ្សែក ខ្សែដៃ ក្រវិល រត់រលះរលាំងចេញពីក្នុងផ្ទះ តំរង់មករកទ្វាររបង ដែលរូបវិរិយាឈរចាំ ។ ទ្វាររបងរបើក វិរិយាលើកដៃសំពះស្រីនោះ ពោលដោយរាបសា :

- ជំរាបសួរមីង ទីនេះជាផ្ទះលោកភិរក្សមែនឬទេ ?

- ចាស នាង គឺផ្ទះហ្នឹងហើយ ។

- ខ្ញុំមានការចង់ជួបលោកភិរក្ស ។

- លោកប្រុស មិនទាន់អញ្ជើញមកពីភ្នំពេញទេ ?

- គាត់ទៅភ្នំពេញពីអង្គាល់ដែរមីង ហើយថ្ងៃណាគាត់អញ្ជើញមកវិញ ។

- លោកអញ្ជើញទៅភ្នំពេញនាព្រឹកមិញ ហើយមកវិញថ្ងៃណាខ្ញុំមិនដឹងទេនាង ព្រោះខ្ញុំគ្រាន់តែជាអ្នកបំរើក្នុងផ្ទះនេះប៉ុណ្ណោះ ធ្វើម្ដេចអាចដឹងកិច្ចការធំ ៗ របស់ចៅហ្វាយនាយ ។

ស្ដាប់សំដីអ្នកបំរើចប់ មុខវិរិយាលេចសញ្ញាខ្វាយខ្វល់ នាងស្រីខាំមាត់រអ៊ូតិច ៗ :

- បើគាត់មិននៅផ្ទះទេ ធ្វើម៉េចទៅហ្ន៎ ?

ស្រីបំរើសង្កេតឃើញអាការប្រែប្រួលរបស់តូចតន់ គាត់ក៏បន្ថី :

- នាងមានកិច្ចការសំខាន់ឬ ? អ្នកស្រីស៊ីថាជាអ្នកគ្រប់គ្រងផ្ទះនេះអាចដោះស្រាយកិច្ចការខ្លះៗ ជំនួសលោកប្រុសបាន ។ នាងអញ្ជើញចូលមក ។

- ចាស អរគុណមីង ។

នាងចាន់នាំមុខវិរិយាតំរង់គ្រឹហា ទួននាងដើរបណ្ដើរ ភ្លៀតគន់លំអ



ភូមិឋានបណ្ដើរ ។ ពេលដែលខ្លួនស្រីកំព្រាប្រាកដនាមាត់ទ្វារផ្ទះ ភាពស្ងប់ស្ងែងពីសភាពតុបតែងនៃគេហដ្ឋាន បានកើតក្នុងអារម្មណ៍ពីតា... សែនប្រណិតប្រទាក់ភ្នែកប្លែកស្រស់ល្អទំនើប ពិតជារត់មកប្រមូលផ្ដុំនាផ្ទៃបន្ទប់ទទួលភ្ញៀវរបស់ភូមិគ្រឹះលោកភិរក្សតែម្ដង ។ តាមជញ្ជាំងរំលោលដីបជរជាស្បៃពណ៌លឿងខ្ចី ធ្លាក់រសាយពីលើពិដាន មកដល់កំរាលព្រំដែលគ្របដណ្ដប់ពាសពេញផ្ទៃឥដ្ឋ កៅអីពូកធំ ៗ ពណ៌លឿងខ្ចី ព័ទ្ធជុំវិញតុទុម៉ែសាក់ ដែលគ្របក្រាលដោយកំរាលស្បៃពណ៌លឿងខ្ចី ដូចរំលោលតាមជញ្ជាំង ។ គ្រឿងសង្ហារិមសព្វបែបដាក់សមសួន តាមរបៀបតុបតែងបែបទំនើប ។ មានទូម៉ៃសាក់តូចល្មមទ្រម៉ាញ៉ៅទំហំ ១០០វ៉ាត់ ទូរទស្សន៍ វីដេអ៊ែ ក៏មានកន្លែងដាក់យ៉ាងប្រទាក់ភ្នែក ព្យ៉ាណូមួយគ្របស្បៃឈរស្ងៀម នៅស្បែរកែវត្រីក្រឹម... សំភារៈក៏ទំនើប ការរៀបចំក៏ទំនង នាំមកនូវសោភ័ណភាពបន្ទប់ឆ្ពុះភាពមនោរម្យអ៊ីម្ល៉េះ... វិរិយាហាក់ភាំងភ្លេចខ្លួនមួយខណៈដ៏ខ្លី ។ ស្រីបំរើញញឹមមើលទៅភ្ញៀវពោល :

- នាងអញ្ជើញអង្គុយ ។

- អ៊ុះ... ចាសមីង ។ "តូចតន់ញញឹមស្ងើរ ដោយអៀននឹងភាពភ័ន្តភាំងរបស់ខ្លួន"

ស្រីបំរើយល់ច្បាស់នូវអាកប្បកិរិយាភ្ញៀវ តែគាត់ធ្វើមិនដឹង ក្នុងនាទីខ្លួនជាអ្នកទទួលភ្ញៀវគាត់បន្តសំដី :

- នាងរង់ចាំបន្តិច ខ្ញុំទៅអញ្ជើញអ្នកស្រីមកជួបនាង ។

- ចាស ។

មីងចាន់ចូលទៅក្នុងផុត វិរិយារភ្នែកសព្វទិសទីនៃគេហដ្ឋាន មុនបង្អស់

នាងប្រទះរូបថតពផ្ទាំង ដែលព្យួរនៅជញ្ជាំងទល់មុខនាង រូបខាងស្តាំជារូបប្រុសម្នាក់ថិតក្នុងវ័យប្រមាណ ២៨ឆ្នាំ ប្រកបដោយវង្ងមុខសែនសង្ហា រូបថតកណ្តាលជារូបក្មេងស្រីអាយុ ២ឆ្នាំ សើចគ្រហាញគួរឱ្យខ្លាញ់ ឯរូបខាងឆ្វេងជារូបនារីវ័យប្រហែល ១៨ទៅ២០ឆ្នាំ សំរស់ស្រស់ស្អាត ញញឹមពព្រាយ លំអដោយអល្ងង្ការជាមាសពេជ្រស្រោចខ្លួន... " ប្រហែល ជារូបថតម្ចាស់ផ្ទះនេះឯង ? " ...នេះជាអារម្មណ៍របស់វិរិយា... នាងស្រីពិនិត្យមើលមុខមាត់នារីក្នុងរូបថត ទំនងជាស្លូតសុភាព តែរូបបុរសដូចជាមានរិទ្ធសំបើម ថ្វីបើមានភាពសង្ហាក្តី ក៏បង្កប់នូវអំណាចអស្ចារ្យ ដែលវិរិយាបានលបគិត ។ កំពុងស្ងួងគំនិត អ្នកស្រីស៊ីថាដើរចេញមករកនាងទាំងពោលផង :

- នាងចាំខ្ញុំយូរទេឯង ខ្ញុំសុំទោសណាំនាង ។

- អ៊ុះ... ចាស ជំរាបសួរអ្នកស្រី មិនជាយូរប៉ុន្មានទេ ទើបតែមុននេះបន្តិចដែរ ។

អ្នកស្រីគ្រប់គ្រងផ្ទះលោកភិរក្ស មានវ័យប្រហែលជាង ៥០ឆ្នាំផ្ទាយគាត់មានទឹកមុខស្រស់ស្រាយ ជីតជាប់នូវភាពញញឹម ដែលជានិស្ស័យកំណើតរបស់គាត់ សន្តានចិត្តគាត់ក៏ទូលាយ មិនចង្អៀតចង្អល់ គាត់ទំលាក់បង្គុយទល់មុខជីតាកំព្រាភ្ជាប់ប្រយោគ :

- នាងមានកិច្ចការអ្វីជាមួយលោកប្រុសភិរក្ស ?

- ចាស ខ្ញុំបានទទួលបញ្ជីពីអ្នកគ្រូសោភា ដើម្បីមកកាន់ទីនេះក្នុងបំណង បង្រៀននាងតូចភារី ។

- អូហ៍ គឺនាងឬជាអ្នកគ្រូថ្មីរបស់នាងតូច ។ លោកប្រុសភិរក្សទន្ទឹងដំណឹងអ្នកគ្រូសោភាជាខ្លាំង តែស្ទាក់ចាត់ឈឹង ទទួលពីម្សិលម៉្ងៃគេផ្តល់ដំណឹង



ថា ទំនិញត្រូវមកដល់ភ្នំពេញពីម្សិល ទើបព្រឹកមិញលោកប្រុសប្រញាប់អញ្ជើញទៅភ្លាមដោយ ផ្តាំខ្ញុំឱ្យចាំទទួលអ្នកគ្រូឱ្យបានសមរម្យ ។ អ្នកគ្រូនៅក្មេងណាស់តែមុខមាត់ទំនងជាឆ្លាតចំណាប់ ។

- អ្នកស្រីសរសើរខ្ញុំយ៉ាំងនេះ ខ្ញុំមិនហ៊ានទទួលទេ ។ សូមកុំហៅខ្ញុំថាអ្នកគ្រូធ្វើអី អ្នកស្រីហៅថាក្មួយៗវិញខ្ញុំសប្បាយរីករាយជាង ។

- មើលទៅក្មួយគួរមាននិស្ស័យមែន មីងសំរេចហៅនាងថា ក្មួយ ។ ឯក្មួយក៏ត្រូវហៅមីងថា មីងៗមកចុះ ។

- ចាស ត្រេកអរណាស់ ដែលអ្នកមីងទំលាក់ខ្លួនមកស្និទ្ធស្នាលជាមួយខ្ញុំ ដែលជាក្មេងកំព្រាឥតរំពឹង ។

- ក្មួយលើកដំកើងមីងពេកហើយ ការពិតមីងពុំមានជាប់សាច់ឈាមអ្វីជាមួយលោកប្រុសទេ មីងគ្រាន់តែជាស្រីមេដោះរបស់លោកប្រុស ទើបលោកប្រុសរាប់អានជាងគេ និងប្រគល់នាទីគ្រប់គ្រងផ្ទះសម្បែងដល់មីង ។ បើនិយាយពីញាតិសន្តាន មីងក៏កំសត់តែឯង ដូចតែក្មួយដែរណាំ ។ ប៉ុន្តែក្មួយកុំបារម្ភ មនុស្សក្នុងផ្ទះដ៏ធំនេះ សុទ្ធសឹងតែជាមនុស្សល្អគួរនឹងរស់នៅជាមួយជាពិសេសលោកប្រុសតែម្តង ដែលចិត្តល្អស្គាល់ទុក្ខធុរៈអ្នករស់ជិតខ្លួន ។

- ខ្ញុំសប្បាយណាស់ គឺជាភព្វសំណាងបំផុតដែលខ្ញុំបានមករស់នៅជិតអ្នកល្អ ៗ អញ្ចឹង ។ ខុសឆ្គងម្តេចម្តា អ្នកមីងកុំមើលបំណាំ ។

- មិនអីទេ ។ យី មិនគួរនាំនាងព្រោកប្រាជ្ញឥតប្រយោជន៍សោះ នាងទើបតែអញ្ជើញមកពីឆ្ងាយ ។ អញ្ជើញនាងទៅសំរាកសិនណាំ ។

ស្រីចំណាស់នាំកាយពីមុខវិរិយា សំដៅបន្ទប់មួយនាជាន់ទី ១ ស្រីទាំងពីរឈប់មុខបន្ទប់ អ្នកស្រីលូកដៃមូលគន្លឹះទ្វារ ដើរចូលទៅមុននារីជាភ្ញៀវ

ពោលពាក្យភ្ញាប់ស្មាមញញឹមផាប់ :

- នេះជាបន្ទប់សំរាប់ក្មួយ ក្នុងបន្ទប់នេះមានបន្ទប់ទឹកស្រាប់ណាក្មួយ ។

វិរិយាភ្ញាក់ផ្អើលនឹងការរៀបចំដ៏ស្អាត ពោរពេញដោយសម្ភារៈមានតំលៃសំរាប់នារីកំព្រាដូចជារូបនាង គ្រែពូកដ៏វិចិត្រ តុសំអាងហ្វ័រមីកាពណ៌សតូចល្មម ទូហ្វ័រមីកាពណ៌ដូចគ្នាសំរាប់ដាក់សំលៀកបំពាក់ តុសរសេរក៏ជាឈើហ្វ័រមីកាពណ៌តែមួយ លើតុមានកូននាឡិការោទិ៍មួយ ថូផ្កាតូចច្រឡឹងមួយ ម៉ាញ៉េ ទំហំ ១៤វ៉ាត់ មួយ ។ វិរិយា រំភើបនឹងសមានចិត្តម្ចាស់ផ្ទះ ជីវិតនាងអស់រយៈ ១៨ឆ្នាំមកហើយ ពុំដែលស្គាល់ របស់របរទំនើបបែបនេះឡើយ តែដួងចិត្តវិរិយាមិនត្រូវការអ្វីហួសពីដៃដែលឈោងចាប់បានដែរ... ការយកចិត្តទុកដាក់ដ៏គួរឱ្យរំភើប ធីតាត្រូវតបស្នងដល់ម្ចាស់គេនូវលទ្ធផលយ៉ាងណានោះ ស្រីកំព្រាត្រូវតែគិតគូរឱ្យមែនទែន... នេះជាគំនិតតូចតន់ ។ អ្នកស្រីស៊ីថាដើរទៅបើកទូខោអាវបង្ហាញនូវសំលៀកបំពាក់ជាច្រើនសំរាប់ សុទ្ធសឹងតែថ្មីស្រឡាង និងជាក្រណាត់ថុនថ្លៃ ។ ស្រីគ្រប់គ្រងផ្ទះ លោកភិរក្ស បែរមកធោមឆើតបន្ថី :

- ខោ-អាវនេះ សំរាប់ក្មួយ ។ លោកប្រុសបានកាត់បំរុងទុកជូន តាំងពីពេលដែលលោកប្រុសចាប់ផ្ដើមំណឹងទៅជូនអ្នកគ្រូសោភាម្ល៉េះ ។ នាងប្រហែលជាឆ្ងល់ថា ម៉េចក៏សំលៀកបំពាក់អស់នេះអាចតម្រូវរូបរាងនាង ប្រការនេះគ្មានអ្វីជាការពិបាកយល់ទេ បើលោកប្រុសកំណត់លក្ខណ្ឌរបស់គាត់ ដើម្បីត្រៀមបំរុង សំលៀកបំពាក់តែប៉ុណ្ណោះ ។

ស្ដាប់ប្រយោគអ្នកស្រីស៊ីថា វិរិយាដូចជាចំណែកពីចិត្តលោកប្រុសភិរក្សមនុស្សនេះទំនងជាខុសគេ សំរាប់រូបនាង ឬមួយអ្នកណាក៏មានឫកពារចិត្តគំនិតដូចលោកភិរក្ស លើកលែងតែមិត្តភក្ដិនាងដែលជាក្មេងកំព្រា ដែលពុកនាង



គ្មានលទ្ធភាពធ្វើអ្វីចំឡែកដូចអ្នកដែលមានទ្រព្យធនដូចឪពុកនាងតូចភារី ។ ទេ ! អ្នកគ្រូសោភា អ្នកគ្រូ លោកគ្រូមួយចំនួន មិនមែនជាមនុស្សបែបលោកភិរក្សដែរ ! គំនិតវិរិយាចេះតែគិតមិនអាចហាមាត់ហើបវាចាអ្វីឡើយ ស្រាប់តែអ្នកស្រីចំណាស់បន្ត :

- ប៉ុន្តែនៅមានលក្ខណ្ឌសំខាន់មួយទៀត គឺលោកប្រុសកំណត់ឱ្យអ្នកគ្រូសោភាជ្រើសរើសបេក្ខជន ជានារីហ្មត់ចត់ មានការតស៊ូជាធំ មានចិត្តរឹងប៉ឹងអត់ធ្មត់បំផុត ។ លោកប្រុសសង្ឃឹមថាអ្នកគ្រូសោភានឹងជួយបំពេញបំណងគាត់ស៊ិតអ្នកគ្រូសោភាមានកូនកំព្រារាប់រយនាក់ ។ " និយាយដល់ត្រឹមនេះអ្នកស្រីញញឹមទះស្មាវិរិយាថ្នមៗ " ...មិនស្មានថាបំណងលោកប្រុសសំរេចលើសក្ដីប្រាថ្នាសោះ ។

- អ្នកមីង អ្វីទៅជាការសំរេចលើសក្ដីប្រាថ្នា ? ក្មួយមិនយល់ទេ ។

- គឺចរិតល្អប្រពៃរបស់ក្មួយ ដែលមានតំលៃកាត់ថ្លៃមិនបានណា ។ នាងដឹងទេ នាងខុសប្លែកពីគ្រូមុន ៗ របស់នាងតូច ។ នៅចំពោះមុខសំភារៈទំនើបៗ និង ខោ-អាវល្អៗ នាងគ្មានចិត្តត្រេកត្រអាលអ្វីបន្តិច ។ ពួកនាងៗ ជាគ្រូទាំង ៥ របស់នាងតូច នៅពេលមីងនាំមកដល់ទីនេះ ពួកគេស្ទុះចូលដោយញញឹមញញែម គេចាប់អង្អែលនេះស្ទាបនោះ លើកសំពត់អាវមក វាស់វែងនឹងខ្លួនប្រាណ គេជញ្ជក់មាត់សរសើររបស់របរទីនេះឥតដាច់ពីមាត់ ។ ឯក្មួយវិញពិតជាមិនរវល់អ្វី ឈរថ្មឹងស្ដាប់មីងដោយការរិះគិត ។ ពិតជាទេព្ដមានភ្នែកមែន ជួយនាំនាងមកអប់រំក្មេងទំរើស ដែលឪពុកខ្វាយខ្វល់នឹងអនាគតកូន សឹងតែវង្វេងវង្វាន់ ។ ទាំងនេះមកពីលោកប្រុសល្អ ទើបចេះតែជួបជាមួយមនុស្សប្រសើរដែរ ។

- អ្នកមីង ខ្ញុំមិនហ៊ានទទួលពាក្យសរសើរទាំងនេះទេ ។

- មែនហើយ ការសរសើរចំពោះមុខ ជូនជាពាក្យបញ្ចើចបញ្ចើ តែចិត្តមីងយ៉ាងណានោះក្មួយនឹងយល់នៅពេលក្រោយ ។ ម្យ៉ាងមីងចាស់ មីងអាចមើលមនុស្សស្គាល់ច្រើនប្រភេទណាំ ។

ចប់សំដី អ្នកស្រីបែរមកចាប់យកប្រអប់តូចមួយ ដែលនៅពីលើខោអាវក្នុងទូ ។ ដៃអ្នកស្រីបើកប្រអប់បង្ហាញនរនាថ វិរិយាយល់ខ្សែកញ្ចូទីន ១ខ្សែ ខ្សែដៃច្នាទីន ១ខ្សែ នាឡិកាចងដៃរបស់មនុស្សស្រីចំនួនមួយ ចិញ្ចៀនត្បូងទទឹម ១វង់ ក្រវិលលំអគ្រចៀកដាំត្បូងដូចចិញ្ចៀនមួយសំរាប់ ។ អ្នកស្រីបិទប្រអប់វិញ ហុចប្រអប់ទៅឱ្យតូចតន់ វិរិយាទទួលកាន់វាដោយឆ្ងល់ងើបមុខសំឡឹងអ្នកស្រីហៀបហើបវាចា តែអ្នកស្រីញីមកាត់សំដីមុននាង :

- ជាអល្ងង្ការសំរាប់រៀបចំខ្លួននាង ដើម្បីឱ្យសមនឹងការរស់នៅក្នុងផ្ទះនេះ ។

- ទេ... ទេ... ខ្ញុំមិនទទួលទេ ខ្ញុំមិនអាចរកប្រាក់សងថ្លៃរបស់អស់នេះបានឡើយ ។ "នាងនិយាយញាប់មាត់ ហុចប្រអប់យ៉ាងលឿនទៅជូនអ្នកស្រី" ។

អ្នកស្រីរុញប្រអប់មករកទ្រូងស្រី ញញឹមតបវាចា :

- ជាអំណោយអនុស្សាវរីយ៍ ដែលលោកប្រុសជូនជាការដឹងគុណគ្រូរបស់កូនស្រីគាត់ គាត់ឥតត្រូវការសំណងវិញទេ ។

- ខ្ញុំមិនយកទេ... ខ្ញុំឥតទាន់បំពេញកិច្ចការអ្វីជូនគាត់ឯណា ។

- កុំប្រកែកអីក្មួយ នេះជាទម្លាប់លោកប្រុស សំរាប់គ្រប់គ្រូរបស់នាងតូចភារីណាំ ។



- ខ្ញុំក៏មានទម្លាប់ដែរ ទម្លាប់ខ្ញុំគឺមិនអាចទទួលរបស់អ្នកដទៃ ដោយឥតថ្នូរឡើយ ។ "នាងព្យាយាមរុញប្រអប់ជាថ្មីទៅឱ្យអ្នកស្រី"

អ្នកស៊ីថាសើចតិចៗ ដោយហួសចិត្ត រាដៃជាសញ្ញាមិនទទួល :

- នាងឆ្លាតណាស់តើ ហាស់... ហាស់... តែតាមគំនិតមីងជាចាស់ទុំ ទម្លាប់នាងគួរកែសំរបទម្លាប់ម្ចាស់ផ្ទះវិញ ទើបជាការប្រសើរ ។

- ទេ... ខ្ញុំត្រូវតែបដិសេធ ព្រោះខ្ញុំបានគិតជាមុនថា អ្វីខ្លះដែលខ្ញុំត្រូវបំពេញ ។ ឯការប្រគល់អំណោយនេះ វា... អ្អឺក... វា... មិន...

- វាមិនប្រាកដជានាងបានគិតដល់ទេ ។ ណេក្តីយ ចាំស្តាប់មីងនិយាយពីរបៀបរបបផ្ទះនេះជំរាបដល់នាងសិនចុះ ។ ដំបូងមីងមានបំណងនឹងជំរាបនាងនៅវេលាម៉ោង ៥រសៀលឯណោះទេ ព្រោះមីងចង់ឱ្យឯងសំរាកកម្លាំងសិន តែមើលទៅក្មួយដូចជាដាច់ខាតមិនទទួលរបស់នេះ ទើបមីងត្រូវជំរាបនាងតែម្តង ។ នាងឃើញហើយផ្ទះដ៏ធំនេះ បង្ហាញពីភាពស្តុកស្តម្ភរបស់ម្ចាស់វា សោតឯម្ចាស់វាក៏មានបុកពាររឿងថ្លៃ មិនចូលចិត្តឱ្យអ្នកណាជំទាស់បំណងខ្លួនទេ ព្រោះលោកប្រុសជាមនុស្ស ហ្មត់ចត់ តែចិត្តថ្លើមពោរពេញដោយការសន្តោសណាស់ដែរ ។ រាល់កិច្ចការអ្វីក៏ដោយ បើលោកប្រុសសំរេចមិនដែលមានការខូចខាតអសារបង់ម្តងណាឡើយ ដោយអ្វីដែលលោកប្រុសបាន "គួរ" សុទ្ធតែបាន "គិត" យ៉ាងល្អិតល្អន់ ។ ដូចជាករណីផ្តល់អំណោយជាមាសប្រាក់និងសំលៀកបំពាក់ខ្លះៗដល់អ្នកត្រូវផ្តល់ វាជាការចាំបាច់របស់អ្នកមានទ្រព្យស្តុកស្តម្ភដូចគាត់ ដែលមាននាទីគិតគូរដល់អ្នករស់ជុំវិញខ្លួន ។ មនុស្សទាំងអស់ក្នុងផ្ទះលោកប្រុស មានមីង នាងសយ នាងភីម នាងចាន់ អ្នកថែសួនម្នាក់ ស្ញូហ្វ័ររថយន្តពីរនាក់ ពួកយើងមានគ្រឿងអលង្ការសំលៀកបំពាក់ និងការហូប

ចុកយ៉ាងសមរម្យ ។ ចុះទំរាំរូបនាងដែលមានឋានៈជាត្រូវបស់នាងតូចភារីរីកតែ ចាំបាច់ត្រូវតែរៀបចំខ្លួនប្រាណឱ្យសមនឹងចិត្តសប្បុរសនៃម្ចាស់ផ្ទះដ៏ធំនេះណាំនាង ។

- តែ... ខ្ញុំ... ខ្ញុំមិនព្រម...

- កុំ "តែ" កុំ "មិនព្រម" អីក្មួយ ។ ថ្ងៃក្រោយក្មួយមុខជាយល់ពីសន្តានចិត្តលោកប្រុសភិរក្សជាមិនខាន ។

វីរិយាខាំមាត់ ជ្រួញចិញ្ចើម នឹករកពាក្យសំរាប់គេចវេះពីការទទួលគ្រឿងអលង្ការ និងសំលៀកបំពាក់ ដែលលោកភិរក្សបានផ្តល់ដល់រូបនាង... ចិញ្ចើមស្រីកំព្រាម្តងជ្រួញ ម្តងរលា ដៃកាន់ប្រអប់នៅតែកាន់ប្រអប់... អ្នកស្រីស៊ីថាដែលតែងតែលបសង្កេតទឹកមុខ និងកាយវិការសមាជិកថ្មី គាត់ញញឹមលើកដៃក្តោបដៃស្រីដែលកាន់ប្រអប់ បន្ទឺពាក្យស្រទន់ :

- នេះជាទម្លាប់ម្ចាស់ផ្ទះ ដែលក្មួយសំរេចចិត្តមករស់ជាមួយណាំ ។ មនុស្សឆ្លាតមិនគប្បីរំខានចិត្តថ្លើម អ្នកដែលយើងត្រូវពឹងពាក់អាស្រ័យដែរ ។ ក្មួយសំរាកចុះ ចាំរសៀលម៉ោង ៥ មីងមកអញ្ជើញនាងដើរមើលសព្វទីផ្ទះ និងជំរាបនាងពីរបៀបរបបក្នុងផ្ទះ ។ មីងទៅហើយណាំ ។

- ចាស អញ្ជើញ "វីរិយាបង្ខំចិត្តឆ្លើយទទួលទាំងទើសទាល់"

អ្នកស្រីស៊ីថាចេញទៅ ទុកនាងទម្លាក់ប្រាណគេងលើពូក ខួរក្បាលធីតារត់រសីបនូវហេតុការណ៍ដែលស្រីជួបប្រទះ នាពេលជើងឈានមកដល់គោលដៅ... អំណោយម្ចាស់ផ្ទះក្នុងបំណងយ៉ាងណាហ្ន៎ ? ជាអំណោយសប្បុរស ឬ ជាជំនួយ ភ្ជាប់បំណងសំងាត់អ្វី ? រស់ជាមួយភាពកំព្រា ទុក្ខវេទនាបង្រៀនឱ្យជីវិតខ្លាចរអាការជំពាក់គុណអ្នកដទៃ បើគ្មានអ្វីជាសំណង ។ សេចក្តី



លោភលន់ចង់មានចង់បានហួសពីសមត្ថភាព ក៏ពុំមែនជាកម្មវត្ថុនៃចំណង់ចិត្ត ។ ធោមស្រីប្រាថ្នាតែមួយចំអែតក្រពះ និងសេចក្តីសុខសាន្ត ប្រាសចាកកង្វល់ដែលជាការបៀតបៀននៃហ្វូងមនុស្សគ្មានវិចារណញ្ញាណមួយចំនួន ។ ធីតាសន្សំសុខ ចៀសឱ្យឆ្ងាយពីចិត្តទុរយស ជួញមិត្តជាជាងចងសត្រូវ ទម្លាប់ម្ចាស់ផ្ទះទើសទាល់ចិត្តនាងជាពន្លឹក ជាទម្លាប់ដែលទំនាស់ចំណង់ចំណូលចិត្តធោមវីរិយា . . . ប៉ុន្តែពេលវេលានេះ ជាពេលរស់ក្រោមការគ្រប់គ្រងទាំងស្រុងរបស់គេ និង ដើម្បីកុំឱ្យពាក្យសន្យាចំពោះអ្នកគ្រូសោភាក្លាយជាពាក្យសំដីឥតន័យផង... ណ្ហើយស៊ូទ្រាំទទួលសិនចុះ ព្រោះវាជាថ្ងៃទីមួយនៃទំនាក់ទំនងនាង និង ម្ចាស់ផ្ទះដ៏ចំឡែក នៅមានថ្ងៃទៅមុខរាប់មិនអស់សំរាប់បំភ្លឺគេពីចិត្តនាង ។ ប៉ុន្តែអំណោយទាំងនេះ នាងគ្រាន់តែទទួលវាទុក ដោយសំរេចចិត្តថាមិនប្រើប្រាស់ឡើយ ។

គិតចុះ គិតឡើង អាការហេវហត់បានផណ្តើមឈ្នះលើអារម្មណ៍នរនាថលុះត្រាតែត្របកភ្នែកទន់បិទចុះលែងដឹងអ្វី...

ម៉ោង ៤.៣០នាទី ស្រីថ្លៃភ្ញារព្រាណពីដំណេក ធោមផើតស្ទុះយ៉ាងលឿន ចារម្ភក្រែងហួសពេលវេលានៃការណាត់ជួប ។ កែវភ្នែកខ្មៅដូចនិលរេរកទ្រនិចនាឡិកាបង្ហាញច្បាស់នូវពេលវេលាគ្មានអ្វីសង្ស័យ ឬភ័យព្រួយ។ វីរិយាប្រញាប់ប្រញាល់ងូតទឹក ផ្លាស់សំលៀកបំពាក់ដែលជារបស់នាងផ្ទាល់ ពុំមែនជាខោ.អាវអំណោយរបស់លោកភិរក្សឡើយ ។ ស្នូរគោះទ្វារលាន់មក វីរិយាយាត្រាទៅបើកទ្វារជូនអ្នកស្រី ព្រមទាំងបន្លើបវាចា :

- សូមអញ្ជើញអ្នកមីង ។

នៅចំពីមុខធីតា រង្វង់ភក្ត្រញញឹមរួសរាយរបស់អ្នកគ្រប់គ្រងផ្ទះ លេច

ចេញមកស្បែរអ្នកស្រី ស្រីបំរើម្នាក់ឈ្មោះនាងភឹម កំពុងឈរកាន់ដៃនាងតូចភារី ដែលមានវ័យប្រហែល ៦ឆ្នាំ ទឹកមុខក្មេងតូចមានភាពធុញទ្រាន់ វាបែរមុខទៅសំឡឹងជញ្ជាំងបន្ទប់ធ្វើហី ហាក់ដូចជានៅពីមុខវា គ្មានវត្តមានមនុស្សចំណូលថ្មី ដែលគួរឱ្យចាប់អារម្មណ៍អ្វីសោះ អ្នកស្រីស៊ីថាលូកដៃអង្អែលក្បាលវានិយាយទន់ភ្លន់ :

- នាងតូច ជំរាបសួរអ្នកគ្រូណាំចៅ ។

ក្មេងងាកមកភ្លាម តែមុខវាគ្មានភាពរីករាយឡើយ វាលើកដៃសំពះទាំងមុខជូរហួញ :

- អ្នកគ្រូ នាងសុំជំរាបសួរ ។

វិរិយាលូកដៃមកបិចថ្ពាល់វា ពោលពាក្យ :

- ស្អាតបាតណាស់នាងតូច មុខមាត់កូនទំនងជាឆ្លាតផងហ្ន៎ ។

- ចាស នាងអត់ឆ្លាតទេ នាងខ្ជិលរៀនណាស់ ធុញសឹងអី" វានិយាយទាំងគ្រវីក្បាលតតាក់បង្ហាញទឹកមុខកាន់តែមិនស្រួល"

វិរិយាលុតជង្គង់ចុះ ដើម្បីឱ្យកំពស់នាង និង ក្មេង មានភាពប្រហាក់ប្រហែលគ្នា ស្រស់ធីតាចាប់ទាញនាងតូចមកអោបអង្អែលក្បាលវាតិច ១ ភ្ជាប់ប្រយោគ :

- នាងរៀនជាមួយអ្នកគ្រូ កូនឥតធុញទេណាំ អ្នកគ្រូនឹងធ្វើឱ្យនាងបានសប្បាយចិត្តមិនខាន ។

- នាងអត់ជឿទេ ។ អ្នកគ្រូណាក៏នាងធុញដែរ ឃើញតែសរសេរៗ រួចអានអក្សរ នាងខ្ជិលណាស់ "វានិយាយផង ប្រឡេះដៃវិរិយាដែលកំពុងអោបវា រួចវាងាកមកនាងភឹម" តោះទៅវិញមីងភឹម ខ្ជិលរៀនខ្ជិលអី ។



និយាយស្ទើរមិនចប់ ភារីរត់ត្រុយយ៉ាងលឿន នាងភឹមហាក់ដូចជាចារម្ភដល់ដំណើររត់ដ៏លឿនរបស់ក្មេង ស្រីបំរើស្ទុះញាប់ជើង ពោលញាប់មាត់ :

- យេប់ ១ នាងតូច ចាំមីងផង ។ កុំរត់ កុំរត់តិចដួលណាំ ។

- នាងអត់នៅជិតអ្នកគ្រូទេ ទៅលេងជាមួយកូនក្រមុំវិញ ។

នាងភឹមប្រឹងរត់លុះតែតាមទាន់ក្មេង ចាប់លើកវាពរដើរទៅមុខ ស្រីតូចភារីអោបនាងបំរើសើចកក្អឹក ។ វិរិយាអង្គុយលុតជង្គង់តាមសំឡឹងអាកប្បកិរិយាភារីដោយរិះគិតភាំង ធីតាភ្លេចទាំងងើប ភ្លេចទាំងវត្តមានអ្នកស្រីស៊ីថាដែលនៅចំពីមុខ ។ អ្នកស្រីលបសង្កេតកាយវិការវិរិយា ដោយស្ងៀមស្ងាត់ ។ វិរិយាងើបឈរឃើត ១ ងាកមកមើលមុខស្រីគ្រប់គ្រងផ្ទះ ស្របពេលអ្នកស្រីកំពុងសំឡឹងមកនាង ធីតាបំរុងហាមាត់ តែអ្នកស្រីកាត់វាចាមកមុន :

- នាងតូចភារី ជាក្មេងទំរើណាស់ក្មួយ ។ ទាំងឪពុកវា ទាំងមនុស្សក្នុងផ្ទះ សុទ្ធសឹងមាននាទីបំពេញចិត្តកូនតូច ព្រោះឪពុកគេស្រឡាញ់គេ អាណិតគេដែលកំព្រាម្ដាយតាំងពីអាយុ ២ខួបម្ល៉េះ ។ មីងជឿថាក្មួយមុខជាជួបការពិបាកច្រើនជាមិនខាន ។

- ចាស ជួបមួយភ្លែត ខ្ញុំមានការបារម្ភដែរអ្នកមីង ។ "នាងញញឹមសើរៗ ព្រមទាំងងក់ក្បាលតិចៗ ក្នុងន័យពិចារណា" ប៉ុន្តែអ្នកមីងហ្ន៎ ក្មេងនេះចូលចិត្តលេងល្បែងអ្វីខ្លះ ?

- ឱ្យតែល្បែង កូននេះដូចជាចូលចិត្តទាំងអស់ ជាពិសេសចូលចិត្តស្ដាប់លោកតាំគេលេងព្យាណូផង ។

វិរិយាងក់ក្បាលតិចៗ ម្ដងទៀត ខាំមាត់ជ្រួយចិញ្ចើម បន្តសំណួរ :

- នាងតូចចូលចិត្តមើលសៀវភៅមានរូបភាពល្អៗឬទេអ្នកមីង ?

- ចូលចិត្ត ។ ចូលចិត្តតែមើលរូបភាពទេនាង ឯអក្សរក្នុងសៀវភៅឥតខ្ទីមើលសោះ ។

- អ៊ីចឹងមិនអីទេមីង នាងតូចមិនគួរឱ្យចារម្តពេកដែរ ។

- មែនឬក្មួយ ? បើដូចសំដីក្មួយ លោកប្រុសមិនដឹងជាត្រេកអរយ៉ាងណាទេ ។

- ខ្ញុំហ៊ានសន្យាថាមិនឱ្យលោកប្រុសខកបំណងទេ ទោះនាងតូចរឹងរូសដូចម្តេចក្តី ។

- សាធុ ៗ ពិតជាទេព្តមានភ្នែកមែន ។ តោះនាង មីងនាំនាងដើរមើលក្នុងផ្ទះ ។

- ចាស អញ្ជើញ ។

អ្នកស្រីស៊ីថាបណ្តើរវីរិយាដើរទស្សនាគ្រប់បន្ទប់ទាំងអស់ នៃគេហដ្ឋាន ។ ក្នុងផ្ទះនេះ មានរបៀបរបបមិនដូចផ្ទះអ្នកដទៃដែលស្រីកំព្រាធ្លាប់ដឹងទេ អ្នកស្រីស៊ីថាមាននាទីគ្រប់គ្រងផ្ទះសម្បែង បានន័យថាមនុស្សក្នុងផ្ទះទាំងអស់មុននឹងសំរេចកិច្ចការអ្វី ទោះជាកិច្ចការធំ ឬ តូច ត្រូវតែផ្តល់ដំណឹងសុំការសំរេចពីលោកស្រី បើសិនជាកិច្ចការនោះមានករណីធ្ងន់ធ្ងរ លោកស្រីនឹងសុំការយល់ព្រមពីលោកភិរក្ស ។ ជាមួយការរៀបរាប់ពីរបៀបរបបសណ្តាប់ធ្នាប់ប្រចាំគេហដ្ឋាន លោកស្រីហាក់មិនភ្លេចពីសេចក្តីសរសើរនូវសប្បុរសធម៌ករុណាធម៌របស់ចៅហ្វាយគាត់សោះ ។ ប៉ុន្តែមានចំណុចសំខាន់ម្យ៉ាងពីបូកការលោកប្រុសម្ចាស់ផ្ទះ ដែលលោកស្រីព្យាយាមបន្ទីស្ទើររាប់ប្រយោគសាសងរវាងគាត់ និងវីរិយា គឺលោកប្រុសហ្មត់ចត់ ម៉ឺងម៉ាត់ និង ផ្ទើងផ្ទៃ ។ ចំពោះវីរិយា គ្រប់ពាក្យពេចន៍ដែលលោកស្រីស៊ីថារ៉ាយរាប់ពីគុណធម៌បូកការចៅហ្វាយនាយរបស់គាត់ វីរិយាមិនទាន់ជឿច្បាស់ ក៏ណត់ថាជាពាក្យពិត ពាក្យសច្ចៈនៅឡើយ នាងលបគិតថា "បើលោកអ្នកមានម្នាក់នេះចិត្តល្អណាស់សប្បុរសណាស់ ប្រពៃណាស់ ម្តេចក៏គ្រូនាងតូចភារី រត់ចោលកូនស្រីរបស់គាត់អស់ចំនួនដល់ទៅ ៥នាក់ ក្នុងរយៈកាលតែ ១ឆ្នាំសោះ ។ តើការចាកចោលរបស់ពួកគ្រូៗ បណ្តាលពីមូលហេតុនៃកូនក្មេងឬ ? ទេ ! តាមភ្នែកវីរិយាមួយភ្លែតដែលបានប្រទះចរិតនាងតូច វីរិយាមិនព្រួយបារម្ភឡើយ ក៏មិនខុសណាពីកម្មវត្ថុចំបងនៃ ការចាកចេញរបស់គ្រូ ៗ ពិតជាមានកត្តាផ្សេងជាមូលហេតុ ។ តើកត្តាអ្វី ? ឪពុកវា ? ឬគ្រូៗទាំងនោះ ? បើនឹងចោទប្រកាន់ពីកំហុសខាងភាគីគ្រូ ៗ ហាក់ដូចជាមិនសូវសមហេតុផល គ្រូមានចំនួន ៥នាក់ ហេតុអ្វីក៏ចិត្តដូចគ្នាទាំង៥នាក់ហ្ន៎ ? ចំលើយគឺពុំមែនជាប្រាកដ អ្វីៗពិតជាកើតពីលោកម្ចាស់ផ្ទះដ៏មានបូកធំនេះហើយ ។ ប៉ុន្តែរបៀបរបបក្នុងផ្ទះក្តី បូកការម្ចាស់ ផ្ទះក្តី ក្មេងកំព្រាដូចវីរិយាទទួលដោយញញឹមឥតតក់ស្លុត ជីវិតវីរិយាធ្លាប់ភ្លក់រសជាតិជូរចត់តឹងណែនដូចគេរឹតអន្ទង ម្តេចគង់វីរិយារស់យ៉ាងរំភើយ ។ ប្រសិនជាក្មេងកំព្រាម្នាក់ដូចវីរិយាជាក្មេងធម្មតា នោះអ្នកគ្រូសោភាប្រាកដជាមិនហ៊ានបញ្ជូននាងមកកាន់គេហដ្ឋានចំឡែកនេះដែរ ។ ម្ចាស់ផ្ទះចំឡែកអ្នកចំណូលថ្មីរឹងប៉ឹង តើលទ្ធផលចុងក្រោយយ៉ាងដូចម្តេចទៅហ្ន៎ ?

# ខគ្គទី ៤

ព្រះអាទិត្យលិចនាទិសបស្ចឹម ទុកនាទីជូនព្រះច័ន្ទបំភ្លឺលោកា បន្ទាប់មករស្មីចន្ទ្រាក៏រលត់សូន្យឈឹង ដូចព្រះទិនករចរយាត្រាតាមកន្លងនៃវេលាកាល. . . ព្រះច័ន្ទ ព្រះអាទិត្យផ្លាស់ប្ដូរវេនគ្នា បង្កើតជាយប់ ឬ ថ្ងៃជានិរន្តរ៍... ថ្ងៃនេះជាថ្ងៃទីពីរដែលស្រីវីរិយាបានរស់ក្រោមដំបូលស្ដុកស្ដម្ភ ហើយជាថ្ងៃដំបូងដែលជីតាកំព្រាចាប់ផ្ដើមបង្រៀនស្រីតូចភារី ។ មើលចុះបុត្រីអ្នកមានអង្គុយធ្វើហី មុខស្មៀកឥតស្ដីមួយម៉ាត់ ទោះជាវីរិយាខិតខំអង្វរលួងលោមស្ទើរជ្រះអណ្ដាតក្ដី ។ វីរិយាឥតធុញទ្រាន់នឹងអាកប្បកិរិយារឹងរូសរបស់ក្មេងទេ នាងព្យាយាមប្រើវាចាទន់ភ្លន់ :

- ស្រីនាង កូនជាកូនល្អណាស់ កូនអានអក្សរតាមអ្នកគ្រូណា៎ ។

- ខ្ជិលណាស់ ។

រយៈពេលជិត ១ម៉ោង កន្លងមក នាងតូចឥតស្ដីនិយាយសូម្បីមួយម៉ាត់ ទើបតែពេលនេះដែលក្មេងរបូតវាចាស្រែកថា "ខ្ជិលណាស់" យ៉ាងខ្លី និងយ៉ាងគំរោះគំរើយគួរឱ្យហួសចិត្ត ។ តែចំពោះវីរិយាពាក្យ "ខ្ជិលណាស់" លាន់ពីមាត់ ភារី ធីតាកំព្រាសប្បាយរីករាយ ដោយមានជំនឿថាក្មេងចាប់ផ្ដើមស៊ុសង្វាក់ជាមួយនាងជាបន្តិចម្ដងហើយ ។ អ្នកគ្រូវ័យក្មេងញញឹមស្រស់ លូកដៃទៅអង្អែលក្បាលវា បន្លឺសូរសៀងស្រទន់ :

- អីយ៉ា ស្រីនាងចេះនិយាយពីរោះណាស់តើ ។ ប្រសិនបើកូនអានអក្សរវិញ បែបពីរោះយ៉ាងណាទេហ្ន៎ ។



- អត់ខ្ចីអានទេ ។ ស្រីនាងអត់ចង់ អត់ចូលចិត្ត ។

- អានបន្តិចទៅស្រីនាង ទើបអ្នកគ្រូស្រឡាញ់កូនណា៎ ។

- ស្រីនាងឥតត្រូវការឱ្យអ្នកគ្រូស្រឡាញ់ទេ បើស្រីនាងមានលោកតាជាអ្នកស្រឡាញ់ស្រីនាងហើយ ។ "វាប្រែខ្នងឱ្យវីរិយា ដោយអាការងរង៉ក់"

- អូហ៎ បើស្រីនាងមិនចង់ឱ្យអ្នកគ្រូស្រឡាញ់ ស្រីនាងចង់បានអ្វីពីអ្នកគ្រូ អ្នកគ្រូនឹងរកឱ្យកូនណា៎ ។

- របស់ស្អីក៏ស្រីនាងអត់ចង់បានដែរ ព្រោះលោកតាទិញឱ្យស្រីនាងគ្រប់សព្វហើយ ។ តែ... អ្នកគ្រូហ្ន... " ក្មេងបែរមុខមករកអ្នកគ្រូ"... អ្នកគ្រូចេះលេងបិទពួនទេ ?

- ស្រីនាងសួរអ្នកគ្រូធ្វើអ្វី ?

- ស្រីនាងចង់លេងបិទពួនជាមួយអ្នកគ្រូណា៎ ។

- ចង់លេងបិទពួនជាមួយអ្នកគ្រូ ! "នាងផ្ទួនពាក្យ"

- ចាស សប្បាយណាស់ណា៎អ្នកគ្រូ "វានិយាយលាយសំណើចទាំងញាក់មុខញាក់មាត់ដោយរីករាយ"

ទឹកមុខវីរិយាសំឡឹងក្មេងក្នុងន័យរិះគិត... យូរបន្តិច ទើបនាងអង្អែលក្បាលក្មេងទំរើសញញឹមមើលមុខវា ស្រីស្រដី :

- អ្នកគ្រូនឹងលេងបិទពួនជាមួយស្រីនាង ។ តែបន្ទាប់ពីលេងចប់កូនត្រូវមករៀនណា៎ ។

- អត់ទេ ស្រីនាងខ្ជិលរៀនណាស់ "វាធ្វើមុខជូរហួញ"

- បើអញ្ចឹងអ្នកគ្រូអត់លេងបិទពួនដែរ ។ "ធីតាពោលទាំងបិចចង្កាវាផង"

ភារីធ្វើមុខស្លឹទំនងជាគិតដល់សំដីអ្នកគ្រូ រួចវាក់ចាប់ដៃវិរិយារលាក់បញ្ឆាក់ :

- តែអ្នកគ្រូលេងបិទពួនជាមួយស្រីនាងជាមុនសិនណាំ ទើបស្រីនាងរៀន ។

- ចាស អ្នកគ្រូយល់ព្រម ។

នៅពេលដែលវិរិយាឆ្លើយទទួលសំណើក្មេង ក្នុងការលេងល្បែងជាមួយភារី ស្របពេលនាងភីមដែលជាស្រីមាននាទីថែរក្សាស្រីភារី បានកាន់ថាសផ្លែឈើ និង ទឹកក្រូចកំប៉ុងក្លាស្សេ មកដល់មាត់ទ្វារល្មម ។ ចំលើយវិរិយាជាមួយក្មេងទំរើស នាំឱ្យចំងល់ដល់ភីម ស្រីបំរើទុចជំហានង័ក់ឈរស្ងៀមក្បែរមាត់ទ្វារបន្ទប់សិក្សា លបស្តាប់ភាសាសាសងរវាងគ្រូ និង សិស្ស ។ សម្លេងស្រាលស្រទន់របស់ចៅហ្វាយតូចលាន់មកប៉ះសោតាភីម :

- អ៊ីចឹង យើងលេងបិទពួនឯសូនច្បារណាំអ្នកគ្រូ ។

- យល់ព្រម ។ តោះស្រីនាង ។

អ្នកគ្រូវ័យក្មេងលូកដៃទៅចាប់ដៃភារី បណ្តើរមករកមាត់ទ្វារ ។ នាងភីមដែលកំពុងលបស្តាប់ ក៏ប្រញាប់វិសៀកខ្លួនយ៉ាងរហ័ស គេចចេញពីទីពួន ។ ជំហានស្រីបំរើរលះរលាំងតំរង់បន្ទប់ស្រីគ្រប់គ្រងផ្ទះសម្បែង អារម្មណ៍ស្រីបំរើដក់ចម្ងល់ជុំវិញរបៀបរបបបង្រៀនដ៏ចំឡែករបស់អ្នកគ្រូក្មេងខ្ចី ដែលយកពេលសិក្សាទៅបំពេញល្បែងសប្បាយជាមួយសិស្សតូចច្រម៉ក់ ។ មកដល់មុខបន្ទប់អ្នកស្រីស៊ីថា ភីមលើកដៃគោះទ្វារ :

- គុក ! គុក !

សំឡេងស្រីចំណាស់លាន់ពីក្នុងបន្ទប់ :



- ចូលមក ។

ភីមរុញទ្វារ ដើរដោយត្រែនៗ ទៅរកអ្នកស្រី អ្នកស្រីស៊ីថាកំពុងអង្គុយលើកៅអីសាឡុង ជូតសំអាតគ្រឿងប្រាក់យ៉ាងផ្ចិតផ្ចង់ ។ សំរឹបជំហានភីមលាន់ស្នូរ អ្នកស្រីចោលភ្នែកមករកភីម ស្រាប់តែយល់ថាសផ្លែឈើនៅពេញប្រៀបដដែល បញ្ជាក់ថាផ្លែផល្លាទាំងនេះ ឥតទាន់មានអ្នកបរិភោគនៅឡើយ អ្នកស្រីជ្រួញចិញ្ចើមសួរ :

- ហ្អាក ចុះម៉េះក៏យកផ្លែឈើនិងទឹកក្រូច ត្រឡប់មកវិញ ?

- ចាស... អ៊ួស... មកពីអ្នកគ្រូ... អ៊ួស... " ភីមហាក់ដូចមិនហ៊ាននិយាយពីគំនិតព្រៀលរបស់វិរិយា ក្នុងការចូលរួមលេងល្បែងបិទពួនជាមួយភារី"

- អ្នកគ្រូវិរិយា មិនអនុញ្ញាតឱ្យនាងតូចញាំផ្លែឈើ ព្បិតខ្លាចរំខាន ពេលសិក្សា ឬ ?

- ចាស... ទេ... មិនមែនទេ គឺអ្នកគ្រូ... អ្នកគ្រូលេង... "ភីមអាក់លែងហ៊ានស្តី"

- វាយ៉ាងម៉េចភីម ? គេបន្ទោសឯង ឬ ? មកពីឯងមិនជំរាបគេឱ្យបានច្បាស់លាស់ពីទម្លាប់នាងតូចដែលត្រូវញាំផ្លែឈើ នៅវេលាម៉ោង ៩ ជារៀងរាល់ថ្ងៃទេដឹង ។ ម្យ៉ាងម៉ោង ៩ ក៏គួរតែឱ្យក្មេងសំរាកលំហែខួរក្បាលបន្ទាប់ពីការរៀន អស់រយៈពីរម៉ោងកន្លងមកដែរណាំ ។

- ចាស... ចាស... រឿងហេតុមិនមែនដូចប្រសាសន៍អ្នកស្រីឯណា ។ ការពិតខ្ញុំស្តាប់ឮដោយដៃឯនឹង នូវរបៀបបង្រៀនដ៏ចំឡែករបស់អ្នកគ្រូវិរិយា អ្នកគ្រូ វិរិយា... អ៊ួស...

អ្នកស្រីនិយាយកាត់ប្រយោគភឹម ទាំងជ្រួញចិញ្ចើម ៖

- ស្អីទៀតហើយភឹម វាមិនសមសោះ ដែលឯងទៅឆ្ងល់ពីរបៀបបង្រៀនរបស់អ្នកគ្រូវិរិយា ។

- អ្នកស្រី កុំអាលបន្ទោសខ្ញុំ សូមអញ្ជើញមកតាមខ្ញុំ អ្នកស្រីមុខជាជ្រាបមិនខាន ។

និយាយចប់ នាងភឹមនាំមុខស្រីគ្រប់គ្រងផ្ទះ សំដៅទៅរានហាលជាន់ទីមួយ ។ នុះហ្ន៎ ភ្នែករបស់ស្រីទាំងពីរ បានប្រទះភាពរត់ប្រដេញគ្នានៃល្បែងបិទពួនរបស់ស្រីតូចភារី និង អ្នកគ្រូក្មេងនាកណ្ដាលសួនច្បារមុខគេហដ្ឋាន ។ ចិញ្ចើមអ្នកស្រីជ្រួញ ភ្នែកសំឡឹងឥតព្រិចទៅរកវិរិយា ភឹមហាមាត់និយាយដោយហួសចិត្ត ៖

- បែបអ្នកគ្រូវិរិយានៅក្មេងមិនទាន់អស់សប្បាយ នឹកអផ្សុកទេដឹង ។ អ្នកស្រីខ្ញុំដូចជាហួសចិត្តពេក ទើបរកនឹកពាក្យអ្វីជំរាបអ្នកស្រីមិនកើត ។ មិនគួរ. . .

អ្នកស្រីលើកដៃរាជាសញ្ញាបញ្ឈប់វាចាភឹម គាត់និយាយ ៖

- អ្នកគ្រូវិរិយាមានវ័យក្មេងមែន តែមិនសមមានគំនិតផ្ដេសផ្ដាស់ មិនយល់ពីពេលវេលា និង នាទីរបស់ខ្លួនទេ ។ ភឹមឯងកុំទាន់សន្និដ្ឋានមុនពីអំពើរបស់អ្នកគ្រូក្មេងនេះ នាងធ្វើអីសុទ្ធតែមានហេតុផល ។ ភឹមឯងឃើញទេ សូម្បីសំលៀកបំពាក់ និងគ្រឿងអលង្ការ ដែលជាអំណោយលោកប្រុស នាងទទួលយកមែន តែឥតប្រើប្រាស់ឡើយ ។ "អ្នកស្រីនិយាយទាំងផ្ដោតភ្នែកទៅរកវិរិយា"

- ប៉ុន្តែ ការដែលនាងនាំនាងតូចលេងបិទពួន នាពេលម៉ោងរៀន វាជា



ការមិនទំនងទេអ្នកស្រី ។

- ខ្ញុំក៏ឆ្ងល់ដែរ ។ អូហ៍ នុះ គេបញ្ឈប់ល្បែងបិទពួនរបស់គេហើយ "គាត់បែរមកមើលមុខនាងភឹមម្ដង និយាយបន្ត"... ម៉ោងប៉ុន្មានហើយភឹម ?

- ចាស ខ្វះ ៨នាទី ទើបម៉ោង ៩ ណាអ្នកស្រី ។

- អូហ៍ មិនទាន់ហួសពេលនាងតូចត្រូវញាំផ្លែឈើទេ ។ ភឹមឯងយកផ្លែឈើ និង ទឹកក្រូចទៅជូនអ្នកគ្រូវិរិយា និង នាងតូច ដើម្បីញាំចុះ ។ ខ្ញុំផ្ដាំណាំ មិនត្រូវនិយាយអ្វីផ្ដេសផ្ដាសពីការប្រព្រឹត្តិរបស់អ្នកគ្រូវិរិយាជាដាច់ខាត ហើយខ្ញុំផ្ដល់នាទីដល់ភឹមឯង ក្នុងការតាមសង្កេតសកម្មភាពអ្នកគ្រូវិរិយាជារៀងរាល់ថ្ងៃ ។

- ចាសអ្នកស្រី ។

ស្រីទាំងពីរបែកគ្នាទៅតាមកិច្ចការរៀងខ្លួន ។ នាងភឹមដើរមកដល់មុខបន្ទប់សិក្សារបស់ភារី នាងឃើញស្រីវិរិយាកំពុងលុតជង្គង់ ផ្ចិតញើសតាមកញ្ចឹងកក្មេងដោយកាយវិការទន់ភ្លន់ និង ទឹកមុខញញឹមញញែម ។ ស្រីកំព្រាបន្ទឺពោលសួរនាងភារី ៖

- សប្បាយឬទេស្រីនាង ?

- ចាស សប្បាយអ្នកគ្រូ ។

- ស្រីនាងហត់ឬទេ ?

- ស្រីនាងអត់ហត់ទេ ស្រីនាងចង់លេងបិទពួនទៀតណាអ្នកគ្រូ ។

- មិនបានទេ ស្រីនាងត្រូវរៀនណា បន្ទាប់ពីសំរាកបន្តិច ។

- អុះ ស្រីនាងភ្លេចឱ្យឈឹង ។

ភឹមកាន់ថាសផ្លែឈើដើរចូលមក ទាំងផ្ទៀងត្រចៀកស្ដាប់ពាក្យពេចន៍

រវាងគ្រូនិងសិស្ស ។ វត្តមានភឹម វីរិយាងើបពីលុតជង្គង់ បែរមកញញឹមទទួលនាងភឹម ។ ស្រីបំរើញញឹមតបទាំងស្រងី :

- អ្នកគ្រូ ម៉ោង ៩ នាងតូចត្រូវញ៉ាំផ្លែឈើ ។

- ស្រីនាងបានប្រាប់ខ្ញុំដែរបងស្រី ទើបខ្ញុំបញ្ឈប់ការលេងបិទពួន មុខម៉ោង ៩ ហ្នឹងណាំ ។

ភឹមលើកថាសផ្លែឈើដាក់លើតុក្បែរវីរិយា ស្រីបំរើងាកមកនិយាយ:

- អ្នកស្រីឱ្យខ្ញុំយកផ្លែឈើមកជូនអ្នកគ្រូ និង នាងតូច ។

- ចាស អរគុណ ។

ភឹមដើរចេញទៅក្រៅ តែនារីពូនចាំលបមើលសកម្មភាពវីរិយា ស្រីកំព្រាលើកផ្លែឈើបញ្ចុកសិស្ស ទាំងពោលពាក្យសរសើរបញ្ចើចបញ្ចើ គៀងគរក្នុងន័យបញ្ចូលចិត្តភារី ឱ្យស្រឡាញ់ការសិក្សា ។ ក្មេងតូចហាក់លុះតាមសំដីវីរិយា ផ្សំនឹងកាយវិការទន់ភ្លន់របស់អ្នកគ្រូក្មេង ជម្រុញចិត្តភារីឱ្យចូលចិត្តវីរិយាដោយមិនដឹងខ្លួន ។ នាងតូចស្ដាប់វីរិយាទាំងញញឹម ជូនវាសើចកក្អឹកកាលបើអ្នកគ្រូក្រមុំ និយាយចំចំណុចកំប្លែងអ្វីមួយ ។ ក្រោយពីការបញ្ចប់ការញ៉ាំផ្លែឈើ វីរិយាចាប់ផ្ដើមបង្រៀនភារី ក្មេងព្រមព្រៀងតាមអ្នកគ្រូឥតប្រកែកជ្រុះបាត់អស់ភាពងរង៉ក់ ។ ការពិតស្រីតូចជាក្មេងឆ្លាតវៃ ប៉ុន្តែមានភាពរឹងរូស ដោយសារតែឪពុកស្រលាញ់ អាណិតថ្នាក់ថ្នមទំរើសពេក រហូតវាដុះទម្លាប់អាក្រក់ពេញចិត្តតែភាពបញ្ចើចបញ្ចើទំយើសរសើរវា ស្អប់ភាពដែលគេបញ្ជាវា គឺវាមានចរិតបញ្ជាទៅលើរូបគេវិញ ទោះជាអ្នកនោះជាមនុស្សចាស់ក្ដី ឬ ក្មេងក្ដី ។ ព្រោះតែនិស្ស័យនេះ ទើបមុនពេលបង្រៀន វាតែងតែមានការទាមទារពីគ្រូឱ្យបំពេញបំណងវាជាមុនសិន បន្ទាប់មកវានឹងយល់ព្រមរៀនតាមគ្រូវិញ ។ ជាមួយគ្រូ



មុន ៗ គ្មានគ្រូណាយល់ព្រមបំពេញលក្ខខ័ណ្ឌ ក្មេងខ្ទីរបស់ភារីបានឡើយ ។ ទីបំផុតគ្រូទាំងនោះត្រូវតែដើរចេញ បើកូនតូចរឹងរូស ឪពុកក្មេងហ្មត់ចត់ ម៉ឺងម៉ាត់យ៉ាងចំឡែក ។ ចំពោះវីរិយា ភាពវេទនាបានបង្រៀនជីវិតនាងអស់ពេល ១៨ឆ្នាំមកហើយ ដូច្នេះគ្មានអ្វីគួររុញរាជាមួយការរឹងរូសរបស់ក្មេងតូចឡើយ វីរិយាប្រឹងប្រែងដណ្ដើមលទ្ធផលពីវា នាងត្រូវតែហ៊ានពុះពារគ្រប់ពេលវេលា ទោះជាត្រូវប្រឡូកជាមួយល្បែងសើចលេងជាមួយកូនសិស្សច្រម៉ក់ ក៏ស្រីកំព្រាឥតញញើត ឬ ដកថយ ។ ប៉ុន្តែទាំងនេះ ជាការពិសោធន៍ស្ទាបស្ទង់ចរិតភារី ក្នុងន័យអប់រំវាជាបណ្ដើរ ៗ មកវិញ ។ ស្រីថៃរក្សាភារីឃើញច្បាស់នឹងភ្នែកនូវអាកប្បកិរិយាវីរិយា ជាមួយចៅហ្វាយតូច នាងលបថយ ទៅបំពេញកិច្ចការខ្លួនយ៉ាងស្ងៀមស្ងាត់ ។

៥ថ្ងៃកន្លងផុត ។

ការសិក្សាលាយនឹងការលេងបិទពួន ប្រព្រឹត្តទៅជាប្រក្រតី ប៉ុន្តែវីរិយាលបលួចបង្កើនពេលរៀន បន្ថយពេលលេង តាមល្បិចលួងលោមក្មេងយ៉ាងប៉ិនប្រសប់ ។ អំពើវីរិយាសំដែង លែងជាកម្មវត្ថុចម្ងល់នៃនាងភឹម និង អ្នកស្រីស៊ីថាទៀតហើយ ស្រីទាំងពីរស្ងើចសរសើរលើការអត់ធ្មត់ ទ្រាំទ្ររបស់អ្នកគ្រូក្មេងយ៉ាងសុទ្ធចិត្ត ហើយនាងភឹមនៅតែរក្សានាទីតាមសង្កេតវីរិយាជាដរាប ។

ថ្ងៃទី ៦ មកដល់ ។

ភារីបុត្រីអ្នកមានកើតជម្ងឺធុញទ្រាន់ជាមួយល្បែងបិទពួន វាកំពុងអង្គុយងរង៉ក់ងៀកបែរខ្នង ទន្ទ្រាំជើងប៉ុងៗស្នើរបែកឥដ្ឋការ៉ូ ដៃក្មេងរុញក្ដារឆ្នួនសៀវភៅ កាតាបគ្រវាត់គ្រវែងចោលតែពីសតែពាស វីរិយាតក្រុកតាមរើសមកទុកដាក់ អ្នកគ្រូកំព្រាអង្អែលក្បាលក្មេង ពោលពាក្យពីរោះ ៗ ក្នុងន័យយល់ព្រម

លេងបិទពួនមុនពេលរៀន ។ ការតបតមកវិញ មានតែភាពងរង៉ក់ យំគគ្រិកគគ្រុកឥតដាច់សូរ សំដីវាម្ដងត្រូវការនេះ ម្ដងត្រូវការនោះ តាមតែចិត្តវាចង់ ។ កាយវិការភារី ប្រៀបដូចដុំថ្មយ៉ាងធំដែលសង្កត់ទ្រូងនាងភីមកំពុងលបស្ដាប់ទាំងភ័យព្រួយ ខ្វាយខ្វល់ជួសស្រីវិរិយា មុខភីមបង្ហាញភាពតានតឹង ដង្ហើមធំលាន់សូរជាញឹកញាប់លាន់ពីទ្រូងស្រីបំរើ ។ ផ្ទុយទៅវិញ សំរាប់វិរិយាដែលប្រៀបដូចជាយុទ្ធជនម្នាក់ធ្លាប់រង វិសេវទុក្ខ គ្រាប់បែកវេទនា គ្រាប់កាំភ្លើងទឹកភ្នែក ទង្វើក្មេងទំរើសមិនខុសណាពីកូនដុំថ្មដ៏តូចល្អិត ដែលចោលដោយដៃក្មេងស្រីមកប៉ះខ្លួននាង... គ្មានចារម្ហ... ឥតកង្វល់... មិនរាថយ វិរិយាដាច់ខាតមិនងងឹតដោយក្ដីអស់សង្ឃឹម នាងនៅតែ ញញឹមបន្ទឹពាក្យស្រទន់ :

- ស្រីនាង ហេតុអីកូនមិនចង់លេងបិទពួនជាមួយអ្នកគ្រូ ?

- ព្រោះស្រីនាងធុញណាស់ លេងបិទពួនយូរៗ អត់សប្បាយទេ ។

- អីចឹងស្រីនាង ចង់លេងអីវិញ ទើបកូនព្រមរៀន ។

- ស្អីក៏មិនលេងដែរ ។ នឹកលោកតា ព្រោះចង់ស្ដាប់ព្យាណូ ឥឡូវលោកតាទៅភ្នំពេញយូរពេកហ៊ឹក. . . ហ៊ឹក. . .

- កុំយំស្រីនាង "នាងលូកដៃជូតទឹកភ្នែកឱ្យវា" បើស្រីនាងចង់ស្ដាប់ព្យាណូ ចាំអ្នកគ្រូដេញឱ្យស្ដាប់ ។

- មែនឬអ្នកគ្រូ ។ បើបានស្ដាប់ព្យាណូ ស្រីនាងរៀនភ្លាមអ្នកគ្រូ ។

- មែនណាំ អ្នកគ្រូនឹងដេញបទពិរោះៗ ឱ្យកូនស្ដាប់ ។ ស្ដាប់ចប់កូនមករៀនជាមួយអ្នកគ្រូវិញណាំ ។

ភារីសើចស្នាញ លើកដៃអាវជូតទឹកភ្នែកខ្សោក ៗ ស្រីវិរិយាចាប់ដៃវាយាត់ជាបន្ទាន់ :



- អេ ៗ កុំជូនទឹកភ្នែកនឹងដៃអាវ ចាំអ្នកគ្រូជូតឱ្យ ។

ជូតទឹកភ្នែកហើយ វិរិយាបណ្ដើរក្មេងសំដៅមាត់ទ្វារ ទាំងមុខពព្រាយដឹតជាប់ភាពញញឹមជាទម្លាប់របស់នាង ។ នាងភីមលបថយទៅបាត់ មុនពេលអ្នកគ្រូ និង សិស្សដើរមកជិតដល់មាត់ទ្វារ ។ កំពុងតែដើរ ក្មេងតូចបន្ទឺពាក្យប៉ប៉ាច់ :

- អ្នកគ្រូហ្ន៎ា ស្រីនាងចង់ស្ដាប់បទ "ស្នេហ៍ដូចជើងមេឃ" ណាំ ។

- ហ្អែក ស្រីនាងធ្លាប់ស្ដាប់បទ "ស្នេហ៍ដូចជើងមេឃ" ដែរឬ ?

- ចាស ជាបទដែលលោកតាតែងតែដេញព្យាណូ និង ច្រៀងឱ្យស្រីនាងស្ដាប់ សឹងតែរាល់ដងណាំអ្នកគ្រូ ។ ស្រីនាងចូលចិត្តស្ដាប់បទហ្នឹងជាងគេ ។

- អូហ៍ ! វិរិយាភ្ញាក់មាត់យ៉ាងខ្លី រួចក៏លែងស្ដី"

ជំហានទាំកាយគ្រូ និង សិស្សតំរង់ព្យាណូ អារម្មណ៍វិរិយាកើតចម្ងល់ពីបញ្ហាបទចម្រៀង "ស្នេហ៍ដូចជើងមេឃ" ។ ហេតុអីលោកភិរក្ស ចេះច្រៀងនិងចេះដេញព្យាណូបទនេះហ្ន៎ ? បើតាមសំដីអ្នកគ្រូសោភា ដែលជាអ្នកនិពន្ធបទខាងលើ អ្នកគ្រូបានប្រាប់នាងថាបទនេះកាលពី ១០ឆ្នាំមុន មានតែមនុស្ស ៣នាក់គត់ ដែលចេះច្រៀង និងដេញព្យាណូ ក្នុងនោះគឺអ្នកគ្រូសោភា និងមនុស្សពីរនាក់ទៀត ពេលនេះវិរិយាបានស្គាល់មនុស្សទីពីរ នៅសល់មនុស្សទី៣ដែលធីតាកំព្រា មិនទាន់បានស្គាល់នៅឡើយ ។ ក្រោយមកអ្នកគ្រូសោភាបានយកបទ " ស្នេហ៍ដូចជើងមេឃ" មកបង្រៀនពួកនាងចំនួន ២០នាក់ ហើយក្នុងចំណោមមិត្តភក្តិនាងទាំង ២០នាក់ មានតែ ៣នាក់ដែរ ដែលចេះបទនេះយ៉ាងស្ទាត់ ។ អ្នកទាំង ៣នាក់ ជំនាន់ក្រោយនេះ មានរូបនាង កក្កដា និង កញ្ញានារី ក្រៅពីនោះមិត្តនាងទាំង ១៧នាក់ ពួកគេមិនសូវជាចាប់អារម្មណ៍ និង ប្រឹង

ប្រែងស្វាធ្យាយ ពីទំនុកច្រៀង និងបទភ្លេងនេះឡើយ ។ ស្រាប់តែពេលមកជាន់ទឹកដីខេត្តកំពង់ចាម វីរិយាបានឮសំដីក្មេងតូចភារីបានបន្ទឹក្នុងន័យថា ឪពុកវាចេះបទ "ស្នេហ៍ដូចជើងមេឃ" ។

អារម្មណ៍រិះគិតជាមួយជំហាននាំប្រាណមកដល់ព្យ៉ាណូ ។ ឆោមឆើតចាប់ផ្តើមច្រៀងរហ៊ុម ៗ និងម្រាមហត្ថាស្រីចុចខ្ទង់ព្យ៉ាណូយ៉ាងរស់រវើក :

- បទ : "ស្នេហ៍ដូចជើងមេឃ"

I. ស្នេហ៍ដូចជើងមេឃៗខ្ពស់ឆ្ងាយដៃ ទ្រូងអូនរហែកស្រែកប្រាប់លោកា
វណ្ណៈអូនក្រក្រដរស្នេហា ព្រួញប្រាក់ប្រហាររបេះដូងភក្តី ។

II. ស្នេហ៍ដូចជើងមេឃៗឥតសង្ឃឹម ដូចភ្លៀងរលឹមតែមិនជោគដី
ជញ្ជីងដូងចិត្តថ្លឹងផ្តាច់និស្ស័យ ម្ខាងជារូបស្រីម្ខាងជាមេឃា ។

R. រលឹកជីវិតបក់បោកប្រឡែង ប្រល័យជាល្បែងលោកិយឫស្យា
ចកអូនរសាត់កាត់ផ្ទៃជលសា ព្រហ្មលិខិតចាររូបអូនក្រក្រី ។

III. ស្នេហ៍ដូចជើងមេឃៗធំល្វឹងល្វើយ ស្នេហ៍ឥតកោះត្រើយស្នេហ៍ប្រុសជីវិ
ជីវិតប្រេះស្រាំទុក្ខសោកញាំញី ស្រីដូចធរណីបងជាវេហាស៍ ។

សំនួនសំនៀងរលត់ ព្យ៉ាណូក៏លែងលាន់សំឡេង ស្នូរទះដៃលាន់ពីហត្ថស្រីតូចភារីឮសួរប្រស់ៗ ជាមួយសំព្ទប្រយោគ :

- ពីរោះណាស់ៗ អ្នកគ្រូច្រៀងពីរោះជាងលោកប៉ាស្រីនាងទៅទៀត ។

វីរិយាញញឹម ងាកមកអង្អែលក្បាលក្មេង ពោល :

- អីយ៉ា ស្រីនាងពូកែបញ្ជោរអ្នកគ្រូណាស់ ។ មោះ យើងដល់ម៉ោងត្រូវរៀនហើយណា៎ ។

- ចាស អ្នកគ្រូ ។



តុរណីហៀបនឹងបណ្តើរនាងតូចចាកចេញពីព្យ៉ាណូ ស្រាប់តែនាងចាន់ដើរមកជិតធីតាពោលពាក្យទាំងហុចសំបុត្រ :

- អ្នកគ្រូ មានសំបុត្រមួយច្បាប់ ជារបស់អ្នកគ្រូ ។

វីរិយាទទួលយកសំបុត្រ នាងញញឹមស្រដី :

- អរគុណ បងចាន់ ។

- ចាស មិនអីទេអ្នកគ្រូ ។

ជាមួយចម្លើយ ចាន់ដើរចេញដើម្បីទៅបំពេញកិច្ចការរបស់នាង ។ វីរិយា លើកសំបុត្រមកមើល នាងលាន់មាត់តិចៗ :

- សំបុត្រ កក្កដា ទេតើ !

ស្រស់ស្រីប្រញាប់សិកសំបុត្រចូលកាបូប បែរមកដឹកដៃភារីតំរង់បន្ទប់សិក្សា ។

Khmer Story Lovers